# ការឃ្លាំមើលការអភិវឌ្ឍន៍នៅកម្ពុជា

ឆ្នាំទី២ លេខទី២
ខែកក្កដា ឆ្នាំ២០០៦



ការវាយតំលៃសូចនាករួម
(ទំព័រទី ១)

សហគមន៍ទន្លេបាសាក់៖
ករណីសិក្សាស្តីពីការ
កាត់បន្ថយភាពក្រីក្រ
និងយុទ្ធសាស្ត្រចតុកោណ
នៅក្នុងទីក្រុងភ្នំពេញ
(ទំព័រទី ៥)

បញ្ហានៅក្នុងច្បាប់ថវិកាជាតិ
សំរាប់កាត់បន្ថយភាពក្រីក្រ
(ទំព័រទី ១០)

NGO Forum
on CAMBODIA

*ការបោះពុម្ពផ្សាយនេះ បានទទួលការឧបត្ថម្ភថវិកាពីសម្ព័ន្ធ
អង្គការមិនមែនរដ្ឋាភិបាលអាស៊ីដើម្បីកែទំរង់វិស័យកសិកម្ម
និងអភិវឌ្ឍន៍ជនបទ (ANGOC)*

# ការវាយតំលៃសូចនាកររួម

## សេចក្តីផ្តើម

នៅឯកិច្ចប្រជុំក្រុមពិគ្រោះយោបល់ស្តីពីកម្ពុជា ឆ្នាំ២០០៦ កាលពីថ្ងៃទី២-៣ ខែមីនា កន្លងទៅនេះ រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អ្នកផ្តល់ជំនួយបានព្រមព្រៀងគ្នាទៅលើសូចនាករតាមដានរួមចំនួន ៦០ ។ សូចនាករនោះបានរៀបរាប់អំពីសកម្មភាពនានាដែលត្រូវអនុវត្តដោយរាជរដ្ឋាភិបាលដែលរួមមាន ១២ វិសយ័ដូចជា ក). ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងភាពក្រីក្រ និងការធ្វើអោយប្រសើរឡើងនូវការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋក្រីក្រកម្ពុជា ខ). ការកែលំអប្រព័ន្ធច្បាប់ និងយុត្តិធមិ ប្រព័ន្ធរដ្ឋបាលសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង គ). ការអនុវត្តនីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការជាដើម ។

ភាពជឿនលឿននៃសូចនាករតាមដានរួមនេះ ត្រូវបានតាមដានរៀងរាល់បីខែម្តងនៅឯកិច្ចប្រជុំគណៈកម្មការសំរបសំរួលរដ្ឋាភិបាល និងម្ចាស់ជំនួយ ។ នៅក្នុងកិច្ចប្រជុំគណៈកម្មការនេះកាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៦ សហគមន៍អង្គការមិនមែនរដ្ឋាភិបាលបានចេញនូវសេចក្តីថ្លែងណ៏ការមួយដោយពិនិត្យមើលលើសូចនាករតាមដានរួមចំនួន ៤១ ហើយ ដែលអាច download បានពីគេហទំព័រ www.ngoforum.org.kh/Development/Docs/docs.htm ។ សេចក្តីថ្លែងការណ៏នេះក៏ភ្ជាប់ជាមួយនូវករណីសិក្សាស្តីពីការបណ្តេញអ្នកស្រុកចេញពីសហគមន៏បាសាក់ (សំបុកចាប) កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៦ កន្លងទៅនេះ ។ ផ្នែកខ្លះខាងក្រោមត្រូវបានដកស្រង់ចេញពីសេចក្តីថ្លែងការណ៏នោះ ហើយស្របទៅតាមរបៀបវារៈនៃកិច្ចប្រជុំណៈកម្មការសំរបសំរួលរដ្ឋាភិបាល និងម្ចាស់ជំនួយ ។

## ច្បាប់ប្រឆាំងអំពើពុករលួយ

i). **សន្ទស្សន៍តាមដានត្រួតពិនិត្យរួមដែលត្រូវបានតាមដានត្រួតពិនិត្យដោយ** NGOs

| គោលដៅ | សកម្មភាពចាំបាច់ |
|---|---|
| ៣. ប្រឆាំងអំពើពុករលួយ | ៣.១. បញ្ចប់ និងអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ដែលផ្អែកទៅតាមការអនុវត្តន៏ល្អ១ ជាអន្តរជាតិ |
| | ៣.២. ផ្សព្វផ្សាយពតិមានអំពីករណីអំពើពុករលួយ និងការកាត់ទោសដែលបានរាយការណ៏នៅរៀងរាល់ពាក់កណ្តាលឆ្នាំម្តង ។ |

ii). **តាមដានត្រួតពិនិត្យលើវឌ្ឍនភាពនៃសកម្មភាពចាំបាច់**

៣.១.សេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយត្រូវបានដាក់ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីកាលពីខែធ្នូ ឆ្នាំ២០០៥ ហើយពេលនេះសេចក្តីព្រាងច្បាប់នេះនៅតែស្ថិតនៅទីស្តីការគណៈរដ្ឋមន្ត្រីនៅឡើយ បើទោះបីជាគេនិយាយថាវាត្រូវបានពិនិត្យដោយក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមសង្កេតការណ៏សេដ្ឋកិច្ច សង្គម និងវប្បធមិ (OBSESS) ហើយក៏ដោយ ។ បើតាមនីតិវិធីច្បាប់ សេចក្តីព្រាងនេះនឹងត្រូវដាក់ជូនយន្តការនៃការត្រួតពិនិត្យមួយផ្សេងទៀតនៅទីស្តីការគណៈរដ្ឋមន្ត្រី គឺកិច្ចប្រជុំអន្តរក្រសួង ។ ចំពោះកាលបរិច្ឆេទកំណត់វិញសេចក្តីព្រាងនេះត្រូវអនុម័តអោយបាននៅដំណាច់ខែមិថុនានេះ ហើយគេសង្ឃឹមថារដ្ឋាភិបាលនៅតែមានពេលវេលាគ្រប់គ្រាន់ ដើម្បីសំរេចអោយបានទៅតាមកាលកំណត់ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ វាហាក់ដូចជាមិនទំនងថា សេចក្តីព្រាងច្បាប់នេះនឹងស្របតាមការអនុវត្តន៏យ៉ាងល្អប្រសើរ ក្នុងកំរិតអន្តរជាតិ ហើយរដ្ឋាភិបាលក៏មិនមានការកែប្រែច្រើនចំពោះសេចក្តីព្រាងលើកមុន១ និងមិនបានខិតខំប្រឹងប្រែងច្រើនដើម្បីលើកកំពស់សេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយនេះអោយស្របទៅតាមមាត្រដ្ឋានអន្តរជាតិឡើយ ។ ដូច្នេះជាការសន្និដ្ឋានគឺគ្មានវឌ្ឍនភាពបន្តិចណាសោះក្នុងការធ្វើអោយប្រសើរឡើងនូវគុណភាពនៃសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ បើទោះបីជាអ្នកជំនាញការអន្តរជាតិ និងសង្គមស៊ីវិលនៅតែបន្តផ្តល់អនុសាសន៏យ៉ាងណាក៏ដោយ ។

វាហាក់ដូចជាមានការភាន់ច្រឡំ ឬកង្វះភាពច្បាស់លាស់ ជាពិសេសរវាង MONASRI និង MoJ ថាតើស្ថាប័នណាមួយដែលជាអ្នកដើរតួនាទីចំបងនៅក្នុងដំណាក់កាលចុងក្រោយនៃការធ្វើសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយនៅពេលដែលគេគិតអំពីបញ្ហាសុខុដុមរមនីយកម្មរវាងច្បាប់ប្រឆាំងអំពើពុករលួយ និងក្រមនីតិវិធីព្រហ្មទណ្ឌ ។ នេះគឺជាឧបសគ្គដ៏ចំបងចំពោះវឌ្ឍនភាពរបស់ច្បាប់នេះ ដោយហេតុថាវាមិនអាចអោយអ្នកជំនាញការ និងសង្គមស៊ីវិលជួយធ្វើអោយប្រសើរឡើង និងជំរុញដំណើរការនេះបាន ។

៣.២.គ្មានព័តិមានណាមួយអំពីករណីអំពើពុករលួយ និងការកាត់ទោសដែលត្រូវបានរាយការណ៏នៅរៀងរាល់ពាក់កណ្តាលឆ្នាំត្រូវបានផ្តល់ជូនដោយរដ្ឋាភិបាលឡើយ ។ប្រហែលពីរខែកន្លងមកនេះ មានករណីមួយដែលត្រូវបានរាយការណ៏អំពីការគៃបន្លំនៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលត្រូវបានស៊ើបអង្កេតដោយអាជ្ញាធរសវនកម្មជាតិ ។ ទោះបីជាយ៉ាងដូចនេះក៏ដោយ ចាប់តាំងពីពេលនោះមក គ្មានព័តិមានមានណាបន្ថែមទៀតត្រូវបានផ្តល់ជូនឡើយអំពីថា តើអ្នកណាខ្លះបានពាក់ព័ន្ធ ឬមួយថាតើមានការចោទប្រកាន់ ឬកាត់ទោសដែរឬទេ ។ បើទោះបីជាមានការដកហូតមន្ត្រីរដ្ឋាភិបាលមួយចំនួនពីបទពុករលួយ និងបំពេញការងារមិនត្រឹមត្រូវក៏ដោយ ក៏គ្មានភ័ស្តុតាងណាមួយត្រូវបានផ្តល់ជូនឡើយ ហើយមនុស្សជាច្រើនបានមើលឃើញថា វាគឺជារឿងនយោបាយ ។

### III. អនុសាសន៍

- NGOs សូមស្នើអោយរដ្ឋាភិបាលគោរពទៅតាមល័ក្ខខ័ណ្ឌនានានៅក្នុង JMIs ក្នុងការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយដែលស្របទៅតាមការអនុវត្តន៍យ៉ាងល្អក៏រិតអន្តរជាតិដោយពិចារណាអំពីអនុសាសន៍ទាំងឡាយដែលអ្នកជំនាញការអន្តរជាតិ និងសង្គមស៊ីវិលបានផ្តល់ជូន ។
- NGOs មិនចង់ឃើញនិទណ្ឌភាពទៀតឡើយជាពិសេសចំពោះអ្នកដែលត្រូវបានរកឃើញថាបានប្រព្រឹត្តអំពើពុករលួយ ដូចក្នុងករណីដែលបានលើកឡើងនៅក្នុងចំណុច ៣.៣ ខាងលើ ។ នេះមានន័យថារដ្ឋាភិបាលមិនត្រឹមតែសងប្រាក់ទៅម្ចាស់ជំនួយវិញ ចំពោះករណីអំពើពុករលួយដែលត្រូវបានរកឃើញនោះទេ ប៉ុន្តែក៏ត្រូវនាំបុគ្គលទាំងនោះមកអោយតុលាការកាត់ទោសផងដែរ ។
- NGOs សូមស្នើអោយចាត់វិធានការបែបនេះផងដែរចំពោះសកម្មភាពណាមួយផ្សេងទៀតនៃអំពើពុករលួយដោយមិនត្រឹមតែគិតអំពីករណីដែលពាក់ព័ន្ធជំនួយបរទេសនោះឡើយ ។
- NGOs គាំទ្រប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រីដែលបានលើកឡើងថា យើងត្រូវប្រឆាំងអំពើពុករលួយសូម្បីតែនៅមុនពេលយើងមានច្បាប់ប្រឆាំងអំពើពុករលួយ ។ នៅក្នុងករណីនេះ NGOs សូមស្នើអោយប្រើប្រាស់ច្បាប់ដែលមានជាធរមានដើម្បីកាត់ទោសចំពោះសកម្មភាពណាមួយនៃអំពើពុករលួយដែលត្រូវបានរកឃើញ ។

## ក្របខ័ណ្ឌច្បាប់ និងតុលាការ

### I. សន្ទស្សន៍តាមដានត្រួតពិនិត្យរួមដែលត្រូវបានតាមដានត្រួតពិនិត្យដោយ NGOs

| គោលដៅ | សកម្មភាពចាំបាច់ |
|---|---|
| ៤. កសាងប្រព័ន្ធច្បាប់ និងយុត្តិធម៌មួយដែលមានដំណើរការល្អ តម្លាភាព និងគណនេយ្យភាពដែលការពារសិទ្ធិបុគ្គលដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ | ៤.១ កសាងនូវក្របខ័ណ្ឌគោលនយោបាយ មួយច្បាស់លាស់ អំពីការទទួលបានព័ត៌មាន |
| | ៤.២ បញ្ចប់ការធ្វើសេចក្តីព្រាង និងអនុម័តច្បាប់មូលដ្ឋានសំខាន់ៗដែលនៅសេសសល់ (ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់តុលាការ) |
| | ៤.៥ ក្នុងពេលដែលកំពុងអនុវត្តដំណើរការ កំណត់អាទិភាព អាទិភាពនឹងត្រូវផ្តល់ជូន :<br>ខ. បញ្ចប់ និងអនុម័តផែនការជាតិ ដើម្បីអនុវត្តច្បាប់ប្រឆាំង អំពើហិង្សាក្នុងគ្រួសារ និងការ ការពារជនរងគ្រោះ<br>គ. បញ្ចប់ការរៀបចំបទប្បញ្ញត្តិទាំងឡាយដើម្បីអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ<br>ឃ. បរិយាយបន្ថែម និងអនុវត្តមាត្រា ១៨ នៃច្បាប់ភូមិបាល<br>ង. អនុម័តយុទ្ធសាស្ត្រ និងបទប្បញ្ញត្តិទាំងឡាយសំរាប់ជនជាតិដើមភាគតិច |

### II. តាមដានត្រួតពិនិត្យលើវឌ្ឍនភាពនៃសកម្មភាពចាំបាច់

៤.១ MONASRI ដែលត្រូវបានប្រគល់ភារកិច្ចនៅក្នុងកិច្ចប្រជុំ CG ដើម្បីដឹកនាំលើបញ្ហានេះ នៅមិនទាន់បានចាត់វិធានការតឹងតែងណាមួយនៅឡើយដោយពួកគេបាននិយាយថាពួកគេនៅតែត្រូវពិភាក្សាសិន និងត្រូវចាត់តាំងជាផ្លូវការពីទីស្តីការគណៈរដ្ឋមន្ត្រី ។ នៅពេលនេះគេនៅមានភាពមិនច្បាស់នៅឡើយថាតើវាពិតជា MONASRI ឬមួយស្ថាប័នរដ្ឋាភិបាលណាមួយផ្សេងទៀតដែលជាអ្នកទទួលខុសត្រូវ ។

៤.២ យោងតាមតំណាង MoJ ដែលបានរាយការណ៍ជូនសម័យប្រជុំនៃរដ្ឋសភាក្នុងកំឡុងពេលពិភាក្សាលើក្រមនីតិរដ្ឋប្បវេណី MoJ កំពុងតែដំណើរការទៅមុខជាមួយនឹងក្រមរដ្ឋប្បវេណី ហើយមានវឌ្ឍនភាពជាច្រើនជាមួយនឹងក្រមនីតិវិធីព្រហ្មទណ្ឌដែលនឹងត្រូវដាក់ជូនសភាជាតិនៅក្នុងពេលឆាប់ៗនេះ ។

៤.៥ខ NGOs សូមវាយតំលៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ MoWA ក្នុងការបង្កើតគណៈកម្មាធិការ ៤ គឺ (១) អប់រំ (២) លើកកំពស់ការយល់ដឹង (៣) ការការពារសង្គម និង (៤) ការការពារតាមផ្លូវច្បាប់ ។ តែទោះបីជាដូច្នេះក៏ដោយផែនការជាតិដើម្បីអនុវត្តច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះកំពុងតែដំណើរការទៅយ៉ាងយឺត ។ អនុក្រឹត្យដែលមានសារៈសំខាន់ក្នុងការផ្តល់គោលការណ៍ណែនាំសំរាប់រៀបចំផែនការមិនទាន់ត្រូវបានអនុម័តនៅឡើយ ។ ការងារលើអនុក្រឹត្យទាំងនេះកំពុងតែដំណើរការ ប៉ុន្តែមិនមានកាលបរិច្ឆេទកំណត់ច្បាស់លាស់សំរាប់អនុក្រឹត្យទាំងនេះឡើយ ។

៤.៥គ NGOs សូមស្វាគមន៍នូវការអនុម័តច្បាប់សំរាប់អនុវត្តនាពេលថ្មីៗនេះពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណ និងការធ្វើផែនទីដីរដ្ឋ និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ។ គេសង្ឃឹមថាការបោះបង្គោលដីរដ្ឋនឹងបញ្ចប់បាននូវការចាប់យកដីដោយខុសច្បាប់ដោយអ្នកឆក់ឱកាសក្នុងស្រុក និងបរទេស ហើយតវិយាបថដែលកំពុងកើតមានសព្វថ្ងៃនេះក្នុងការចង់ចំណេញក្នុងរយៈពេលខ្លីនឹងផ្លាស់ប្តូរឆ្ពោះទៅរកការប្រើប្រាស់រយៈពេលយូរប្រកបដោយនិរន្តរភាព និងការគ្រប់គ្រងទ្រព្យសម្បត្តិធម្មជាតិរបស់រដ្ឋដោយមានការចូលរួមពេញលេញពីសំណាក់ប្រជាជននៅមូលដ្ឋានដែលពឹងផ្អែកលើធនធាន និងសាធារណជនទូទៅ ។ ប៉ុន្តែ NGOs មានការព្រួយបារម្ភថាការកំណត់អត្តសញ្ញាណ និងធ្វើផែនទីដីរដ្ឋមិនត្រូវបានតភ្ជាប់អោយបានពេញលេញទៅនឹងដំណើរការនៃការធ្វើផែនទីផ្សេងទៀតឡើយ ដូចជាការធ្វើផែនទីបរិមាណគ្របដណ្តប់ព្រៃឈើ ផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម ដើម្បីអភិវឌ្ឍមូលដ្ឋាន និងការធ្វើផែនទីដីសម្បូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ។

៤.៥ឃ ពាក់ព័ន្ធនឹងការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីដកហូតមកវិញនូវការគ្រប់គ្រងលើប្រតិបត្តិការលក់ដូរដីដែលពាក់ព័ន្ធដីរដ្ឋ NGOs ស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ដើម្បីស្រាយបំភ្លឺអំពីវិសាលភាព និងការអនុវត្តន៍មាត្រា ១៨ នៃច្បាប់ភូមិបាល ។ ត្រូវចាត់វិធានការជាបន្ទាន់ដោយហេតុថាជនជាតិដើមភាគតិច និយាយដោយឡែក កំពុងជួបប្រទះ

នូវការលំបាកយ៉ាងធ្ងន់ធ្ងរដែលបណ្តាលមកពីការកើនឡើងនូវការផ្ទេរកម្មសិទ្ធិដីនៅក្នុងសហគមន៍របស់ពួកគេ ។

៤.៥ង នៅក្នុងបរិការណ៍នេះ NGOs សូមស្វាគមន៍នូវកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ដើម្បីកសាងយុទ្ធសាស្ត្រ និងបទប្បញ្ញត្តិទាំងឡាយសំរាប់ការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច ។ ការចុះបញ្ជីដីនៅក្នុងសហគមន៍ពីរសាកល្បងជានីតិបុគ្គលនៅខេត្តរតនគីរី បានជិតទៅដល់ទីបញ្ចប់ហើយ ហើយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៅក្រសួងមហាផ្ទៃបានសំដែងនូវការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីបញ្ចប់សហគមន៍សាកល្បងមួយផ្សេងទៀត នៅក្នុងខេត្តរតនគីរីនៅក្នុងពេលឆាប់ៗនេះ ។

### III. អនុសាសន៍

- (៤.១) ដើម្បីជួយប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ រាជរដ្ឋាភិបាលគួរជំរុញអោយបានលឿននូវការបង្កើតក្របខ័ណ្ឌច្បាប់មួយស្តីពីការទទួលបានព័ត៌មានដូចដែលលើកឡើងនៅក្នុង CG JMIs ។
- (៤.៥គ) NGOs មានការព្រួយបារម្ភថា ការកំណត់អត្តសញ្ញាណ និងការធ្វើផែនទីដីរដ្ឋមិនត្រូវបានតភ្ជាប់គ្នាអោយបានពេញលេញទៅនឹងដំណើរការនៃការធ្វើ ផែនទីផ្សេងទៀត ដូចជាការបោះបង្គោលដីព្រៃ និងតំបន់ការពារផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមដើម្បីអភិវឌ្ឍន៍មូលដ្ឋាន និងការធ្វើផែនទីដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ។ លើសពីនេះទៅទៀតក្រុមការងារស្រុក/ខ័ណ្ឌ គួរទទួលបានការគាំទ្រថវិកា និងបច្ចេកទេសគ្រប់គ្រាន់ដើម្បីបំពេញតួនាទី និងអាណត្តិរបស់ពួកគេនៅក្នុងដំណើរការកំណត់អត្តសញ្ញាណ និងធ្វើផែនទីដីរដ្ឋ ។
- (៤.៥ឃ) មុនពេលអនុវត្តដោយពេញលេញនូវមាត្រា ១៨ មានតំរូវការជាបន្ទាន់មួយអោយរាជរដ្ឋាភិបាលកម្ពុជាប្រកាសជាសាធារណៈថា រាល់ប្រតិបត្តិការទិញ លក់ ដូរ ដីនៅក្នុងតំបន់ជនជាតិដើមភាគតិចគឺជាការខុសច្បាប់ហើយអ្នកទិញដីនឹងមិនទទួលបានប័ណ្ណកម្មសិទ្ធិដីដែលបានទិញដោយខុសច្បាប់នោះឡើយ ។
- (៤.៥ង) យោងតាមការកើនឡើងយ៉ាងលឿននៃការផ្ទេរកម្មសិទ្ធិដី NGOs ចង់មើលឃើញនូវការអនុវត្តន៍នូវដំណើរការមួយដែលអាចទទួលបានជាទូទៅសំរាប់ការទទួលស្គាល់សហគមន៍ដោយស្របច្បាប់ថាជាជំហានចាំបាច់ទីមួយឆ្ពោះទៅការចុះបញ្ជីដីសមូហភាពរបស់ពួកគេ ។
- (៤.៥ង) ប៉ុន្តែចំពោះមាត្រដ្ឋានអន្តរជាតិ និងសិទ្ធិជាមូលដ្ឋានរបស់ជនជាតិដើមភាគតិចវិញ NGOs យល់ឃើញថាមានភាពចាំបាច់ក្នុងការធ្វើអោយលក្ខន្តិកៈកាន់តែប្រសើរឡើងថែមទៀត ។ មុនពេលចាប់ផ្តើមធ្វើលក្ខន្តិកៈសំរាប់សហគមន៍ទីបីនៅខេត្តមណ្ឌលគីរី NGOs សូមស្នើអោយមានដំណើរការត្រួតពិនិត្យមួយដោយមានការចូលរួម ពីតំណាងជនជាតិដើមភាគតិច និងអង្គការសង្គមស៊ីវិល ។

ទន្ទឹមនឹងនេះ NGOs ក៏សង្ឃឹមថានីតិវិធីសំរាប់ការចុះបញ្ជីនឹងត្រូវបានបញ្ជាក់ច្បាស់លាស់នៅក្នុងឯកសារយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយមួយស្តីពីការចុះបញ្ជីដីធ្លីរបស់ជនជាតិដើមភាគតិចដែលនៅពេលនេះកំពុងត្រូវបានកសាងដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយ ដីធ្លី និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ។ ផ្អែកលើបទពិសោធន៍នៃការពិគ្រោះយោបល់លើអនុក្រឹត្យ ស្តីពីការគ្រប់គ្រងដីរដ្ឋ និងសម្បទានដីសេដ្ឋកិច្ច NGOs ត្រៀមខ្លួនជាស្រេចដើម្បីគាំទ្រដល់ក្រសួងក្នុងការរៀបចំការពិភាក្សាជាសាធារណៈលើឯកសារយុទ្ធសាស្ត្រនេះជាមួយសហគមន៍ជនជាតិដើមភាគតិច និងសង្គមស៊ីវិល ។

## ក្របខ័ណ្ឌនៃការតាមដានត្រួតពិនិត្យ NSDP

### I .សន្ទស្សន៍តាមដានត្រួតពិនិត្យរួមដែលត្រូវបានតាមដានត្រួតពិនិត្យដោយ NGOs

| គោលដៅ | សកម្មភាពចាំបាច់ |
|---|---|
| ១. NSDP ត្រូវបានតាមដានត្រួតពិនិត្យប្រចាំឆ្នាំ | ១.១ កសាង និងអនុវត្តនូវក្របខ័ណ្ឌមួយ ដើម្បីតាមដានត្រួតពិនិត្យមើលនូវការអនុវត្ត NSDP និងរៀបចំការត្រួតពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំ ចំពោះការអនុវត្ត NSDP |

### II.តាមដានត្រួតពិនិត្យលើវឌ្ឍនភាពនៃសកម្មភាពចាំបាច់

១.១ NGOs ស្វាគមន៍ចំពោះការបន្តអោយមានឱកាសចូលរួមនៅក្នុងក្រុមការងារបច្ចេកទេសស្តីពីការធ្វើផែនការ និងការកាត់បន្ថយភាពក្រីក្រ (TWG-PPR) ហើយក្នុងនាមជាសមាជិកស្នូលរបស់ TWG-PPR NGOs ប្តេជ្ញាចិត្តចូលរួមចំណែកជាវិជ្ជមានចំពោះគោលបំណងរបស់ក្រុម ។ NGOs ស្វាគមន៍នូវកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងផែនការក្នុងការកសាងនូវក្របខ័ណ្ឌមួយដើម្បីតាមដានត្រួតពិនិត្យ NSDP ។ ប៉ុន្តែគេបានកត់សំគាល់ឃើញថា ក្របខ័ណ្ឌសំរាប់ធ្វើការតាមដានត្រួតពិនិត្យនេះមិនទាន់មានភាពពេញលេញនៅឡើយដោយនៅពេលនេះវានៅខ្វះខាតសន្ទស្សន៍ទទួលបាន/លទ្ធផលដែលនឹងត្រូវកសាងឡើងដោយក្រសួង ខ្សែទទឹងទាំងឡាយដូចដែលក្រសួងផែនការបានស្នើសុំនៅក្នុងលិខិតរបស់ខ្លួនទៅក្រសួងខ្សែទទឹងទាំងនេះ ។

### III. កង្វល់

- នៅក្នុងកិច្ចប្រជុំចុងក្រោយរបស់ NGOs កាលពីខែមេសាគេបានបញ្ជាក់ច្បាស់ថា អត្ថបទ NSDP ដែលបានធ្វើបច្ចុប្បន្នភាពនឹងមិនអាចចេញផ្សាយបាននៅខែមិថុនាតាមកាលកំណត់នោះទេ ។ បើគ្មាន "ការត្រួតពិនិត្យបឋម" របស់ NSDP នេះទេ វានៅតែមានគម្លាតជាច្រើននៅក្នុងអត្ថបទសព្វថ្ងៃនេះ ។ កង្វល់ធំៗពីររបស់ NGOs គឺកង្វះខាតនូវការដាក់បញ្ចូលផែនការថ្នាក់មូលដ្ឋាន និងតាមវិស័យពិស្តារ និងកង្វះខាតចំណងទាក់ទងរវាង NSDP និងទំនាក់ទំនងទៅនឹង PIP ២០០៧-២០០៩ MTEF ២០០៧-២០១១ និងថវិកាប្រចាំឆ្នាំ ២០០៧ ។
- លើកលែងតែក្រសួងសុខាភិបាល និងក្រសួងអប់រំផែនការតាមវិស័យដែលនឹងដាក់អោយដំណើរការ NSDP

គឺអាចថាគ្មានឬមិនបានចែករំលែកជាមួយម្ចាស់ជំនួយ និងសហគមន៍ NGOs ទេ ។ ក្របខ័ណ្ឌក្នុងការតាមដានត្រួតពិនិត្យដ៏ទូលំទូលាយមួយសំរាប់ NSDP អាចកើតចេញមកពីផែនការតាមវិស័យដែលទំនងជានឹងត្រូវសំរេចបាននៅមុនដំណាច់ខែមិថុនា ។ កាលបរិច្ឆេទកំណត់សំរាប់ក្រសួងខ្សែទទឹងក្នុងការបញ្ចប់ផែនការរបស់ពួកគេក៏មិនមានភាពច្បាស់លាស់ដែរ ។

- លេខាធិការដ្ឋាន NSDP គ្មានទំរង់រួមសំរាប់ដំណាក់កាលនៃការកសាងផែនការតាមវិស័យដោយក្រសួងខ្សែទទឹងឡើយ ។ ប្រសិនបើក្រុមការងារបច្ចេកទេសនៅក្នុងវិស័យផ្សេងៗគ្មាចង់សំរបសំរួលកសាងផែនការទាំងនេះគេនឹងទទួលបានការណែនាំមួយចំនួនពីក្រសួងផែនការអំពីទំរង់ណាមួយនៃផែនការ និងលក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើសសន្ទស្សន៍ ។

### III. អនុសាសន៍

- ក្រសួងផែនការចាំបាច់ត្រូវធ្វើការតាមដានជាមួយក្រសួងខ្សែទទឹងទាំងអស់ដើម្បីរកអោយឃើញនូវស្ថានភាពនៃការកសាងផែនការតាមវិស័យ ។ បន្ទាប់មកក្រសួងផែនការចាំបាច់ត្រូវសហការជាមួយម្ចាស់ជំនួយដើម្បីបំពេញគំលាតផ្នែកសមត្ថភាពដែលអាចត្រូវបានកំណត់ ។
- ចំពោះការអភិវឌ្ឍន៍កសិកម្ម និងជនបទដែលជាវិស័យអាទិភាពនោះ ផែនការទាំងនេះចាំបាច់ត្រូវរៀបចំនៅក្នុងរយៈពេល ៣ ខែ ខាងមុខដើម្បីអោយមានការជះឥទ្ធិពលនៅក្នុងវិភាជន៍ថវិកាឆ្នាំ២០០៧ និង PIP ២០០៧-២០០៩ ។
- ផែនការតាមផ្នែកទាំងអស់គួរតែត្រូវបានពិភាក្សាដោយបើកចំហរជាមួយក្រុមការងារបច្ចេកទេសទាំងអស់ ។

## លើកកំពស់ជីវភាពប្រជាជនក្រីក្រនៅជនបទ

### I. សន្ទស្សន៍តាមដានត្រួតពិនិត្យរួមដែលត្រូវបានតាមដានត្រួតពិនិត្យដោយ NGOs

| គោលដៅ | សកម្មភាពចាំបាច់ |
|---|---|
| ៨. លើកកំពស់ជីវភាពរបស់ប្រជាជនក្រីក្រនៅជនបទ កាត់បន្ថយភាពក្រីក្រ ជាពិសេសនៅតំបន់ជនបទ និងលើកកំពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយផ្អែកលើអាទិភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិសំរាប់ឆ្នាំ ២០០៦-២០១០ | ៨.២ បង្កើតយន្តការមួយ និងផ្សព្វផ្សាយព័ត៌មានអោយបានទៀងទាត់ អំពីសម្បទានដីសេដ្ឋកិច្ច ស្របទៅតាមសេចក្តីណែនាំរបស់ នាយករដ្ឋមន្ត្រី ចុះថ្ងៃទី ៣០ មិថុនា ២០០៥ |
| | ៨.៣ ចាត់វិធានការសមស្របដើម្បីរំលេចអោយឃើញនូវអាទិភាពរបស់វិស័យជលផលសំដៅលើកកំពស់ជីវភាពរបស់សហគមន៍នៅជនបទ នៅក្នុងផែនការអភិវឌ្ឍឃុំ ស្រុក និងខេត្ត ក៏ដូចជាក៏រិតនៃការផ្តល់មូលនិធិរបស់ម្ចាស់ជំនួយ |
| | ៨.៤ ដើម្បីលើកកំពស់របស់ប្រជាជនក្រីក្រនៅជនបទ ៥០០គ្រួសារត្រូវមានសិទ្ធិតាំងទីលំនៅលើដីសម្បទានសង្គមកិច្ច ដោយមានការជួយទ្រទ្រង់ជីវភាព ហើយយ៉ាងហោចណាស់ដីសមស្របចំនួន ១០.០០០ហិកតា ត្រូវបានបញ្ជាក់ថាមានទំនេរសំរាប់សម្បទានដីសង្គមកិច្ច ។ |

### II. តាមដានត្រួតពិនិត្យលើវឌ្ឍនភាពនៃសកម្មភាពចាំបាច់

៨.២ NGOs ស្វាគមន៍ការចេញផ្សាយព័ត៌មានស្តីពីសម្បទានដីសេដ្ឋកិច្ចនៅក្នុងវែបសាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដោយចាត់ទុកជាជំហានមួយយ៉ាងសំខាន់ក្នុងការបង្កើនតម្លាភាពចំពោះការប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិរបស់រដ្ឋ ។ ប៉ុន្តែ NGOs ក៏កត់សំគាល់ឃើញថាព័ត៌មាននេះនៅមិនទាន់គ្រប់គ្រាន់ ព្រមទាំងមិនទាន់បានធ្វើបច្ចុប្បន្នភាពក្នុងវែបសាយនៅឡើយ ។ មានព័ត៌មានតិចតួចប៉ុណ្ណោះដែលពាក់ព័ន្ធនឹងសម្បទានដែលមិនទាន់បានចុះហត្ថលេខាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅឡើយ ។ ទន្ទឹមនឹងនេះ NGOs ក៏មានការព្រួយបារម្ភអំពីគុណភាពនៃការផ្តល់កូអរដោនេ ដោយហេតុថាគេមិនបានបញ្ជាក់អោយច្បាស់ថាតើទិន្នន័យបែបណាដែលត្រូវបានប្រើប្រាស់ដើម្បីរកព័ត៌មានទាំងនេះ ។

៨.៣ NGOs ស្វាគមន៍នូវការអនុម័តច្បាប់ជលផលថ្មី ដែលត្រូវបានឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ កាលពីថ្ងៃទី ២៤ ខែឧសភា ។

៨.៤ NGOs ស្វាគមន៍នូវរាល់វិធានការដែលត្រូវបានធ្វើឡើងដោយក្រុមរៀបចំថ្នាក់ជាតិសំរាប់ការបែងចែកដីសំរាប់គំរោងអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ច ដើម្បីអោយមានការចូលរួមពីសំណាក់ NGOs និងសង្គមស៊ីវិលនៅក្នុងការអនុវត្តគំរោងសាកល្បងពីរ ស្តីពីសម្បទានដីសង្គម នៅក្នុងខេត្តកំពង់ចាម និងខេត្តក្រចេះ ។ គេសង្ឃឹមថាកិច្ចសហប្រតិបត្តិការនេះ នឹងបន្តទៅទៀតនៅក្នុងអនាគត ។ ទោះជាយ៉ាងណាក្តី ជាទូទៅ NGOs មានការព្រួយបារម្ភអំពីដំណើរការរកដីទំនេរសំរាប់សម្បទានដីសង្គមកិច្ច និងការជ្រើសរើសអ្នកទទួលផល ។

### III. អនុសាសន៍

- (៨.២) កូអរដោនេដែលបានផ្តល់ជូនសំរាប់សម្បទានដីសេដ្ឋកិច្ចចាំបាច់ត្រូវមានកំណត់ជាស្តង់ដា ហើយព្រំប្រទល់នៃសម្បទានគួរត្រូវបានដាក់បញ្ចូលនៅក្នុងផែនទីគ្រប់ជ្រុងជ្រោយមួយ ដែលក៏នឹងរួមបញ្ចូលនូវព័ត៌មានអំពីសម្បទានរ៉ែ តំបន់អភិវឌ្ឍន៍យោធា និងសម្បទានផ្សេងទៀតដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល ។ អត្ថបទរបាយការណ៍ទាំងស្រុងអំពីអធិការកិច្ច E/SIAs និងការងារ និងការប្តេជ្ញាចិត្តផ្នែកសង្គមសំរាប់សម្បទានដីសេដ្ឋកិច្ចគួរផ្សព្វផ្សាយជាបន្ទាន់ ។

ស្របតាម JMIs 4.5គ និងផ្អែកលើជោគជ័យនៃ JMIs ក្នុងឆ្នាំកន្លងមកពាក់ព័ន្ធនឹងការអនុម័តច្បាប់ដីធ្លីសំខាន់ៗ (សន្ទស្សន៍ឆ្នាំ២០០៥ សំរាប់វិស័យកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិសន្ទស្សន៍ទី ១ : NGOs សូមស្នើអោយម្ចាស់ជំនួយ និងរាជរដ្ឋាភិបាលកម្ពុជាត្រួតពិនិត្យឡើងវិញជាបន្ទាន់នូវសម្បទានដីសេដ្ឋកិច្ចដែលមិនបានផ្សព្វផ្សាយដើម្បីអោយស្របទៅតាមច្បាប់ និងអនុវត្តរាល់វិធានការសមស្រប) ។

- (៨.៣) NGOs សូមស្នើអោយម្ចាស់ជំនួយពាក់ព័ន្ធ និងនាយកដ្ឋានជលផល ធ្វើការសំរបសំរួលសកម្មភាពផ្សព្វផ្សាយច្បាប់ជលផល ដើម្បីជៀសវាងការជាន់ភារកិច្ចគ្នា (និងការផ្តល់មូលនិធិ)។ ទន្ទឹមនឹងនេះ គួរធ្វើផែនការសំរបសំរួលដើម្បីចាប់ផ្តើមព្រាងរាល់ប្រកាស អនុក្រឹត្យនានា ដែលចាំបាច់សំរាប់អនុវត្តច្បាប់ថ្មីអោយមានប្រសិទ្ធភាព។
- (៨.៤) យន្តការផ្តល់យុត្តិធម៌មួយដែលមានលក្ខណៈសាមញ្ញ និងប្រសិទ្ធភាព ចាំបាច់ត្រូវដាក់អោយដំណើរការដើម្បីធានាថា សម្បទានដីសង្គមកិច្ចពិតជានឹងផ្តល់ផលប្រយោជន៍ដល់គ្រួសារដែលគ្មានដីធ្លី និងគ្រួសារកសិករក្រីក្រដែលគ្មានដី។ NGOs សូមលើកឡើងសារជាថ្មីនូវអនុសាសន៍របស់ខ្លួន ដែលមាននៅក្នុងសេចក្តីថ្លែងការណ៍ NGO ចំពោះកិច្ចប្រជុំ CG ឆ្នាំ ២006 ថាមានតែដីទំនេរ និងដីគ្មានព្រៃប៉ុណ្ណោះដែលគួរបែងចែកសំរាប់សម្បទានដីសង្គមកិច្ច។

# សហគមន៍ទន្លេបាសាក់៖ ករណីសិក្សាស្តីពីការកាត់បន្ថយភាពក្រីក្រ និងយុទ្ធសាស្ត្រចតុកោណ នៅក្នុងទីក្រុងភ្នំពេញ

## សេចក្តីផ្តើម

ខណៈពេលដែលម្ចាស់ជំនួយនិងតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជាជួបគ្នាដើម្បីពិនិត្យលើការវិវត្តន៍លើសន្ទស្សន៍ តាមដានរួមដែលបានឯកភាពគ្នាសំរាប់ឆ្នាំ ២006 អង្គការមិនមែនរដ្ឋាភិបាល សូមគោរពស្នើសុំអោយសមាជិកដែលចូលរួមនៅក្នុងដំណើរការនៃកិច្ចប្រជុំក្រុមពិគ្រោះយោបល់ចំណាយពេលវេលាដើម្បីពិនិត្យមើលបញ្ហានានាដែលកំពុងកើតមាននៅចំពោះមុខ (មាត់ទ្វារ) ពួកគេ។

នៅក្នុងទីក្រុងភ្នំពេញ ការបណ្តេញអ្នកភូមិក្រីក្រទៅកាន់ជាយក្រុងបានបង្កើតជាសំនួរអំពីការប្តេជ្ញាចិត្តដែលបានសន្យារបស់អាជ្ញាធរចំពោះការកាត់បន្ថយភាពក្រីក្រ និងការធ្វើអោយប្រសើរឡើងនូវការផ្តល់សេវាសាធារណៈ។ មិនមានកន្លែងណាមួយដែលអាចជាភស្តុតាងជាក់ស្តែងជាងករណីភូមិ*សំបុកចាប*[១] នេះទេ។

## សាវតា

ភូមិសំបុកចាប ស្ថិតនៅប្របមាត់ទន្លេបាសាក់ ជាប់នឹងអាគារកាស៊ីណូណាហ្គា និងក្រសួងដែលទើបបង្កើតថ្មី គឺក្រសួងទំនាក់ទំនងសភា ព្រឹទ្ធសភា និងអធិការកិច្ច (MoNASRI)។ ដោយមានលំនៅដ្ឋានរបស់អ្នកភូមិប្រមាណ ២00 គ្រួសារ សហគមន៍នេះគឺជាតំបន់ប្រជាជនក្រីក្របំផុតមួយនៅក្នុងទីក្រុងភ្នំពេញ។ ក្រុមហ៊ុនស្ួរ ស្រ៊ុន បានប្រកាសថាជាម្ចាស់កម្មសិទ្ធិ[២] លើដីនេះ និងបានផ្តើមគំនិតចំពោះការបណ្តេញប្រជាជន និងការផ្លាស់ប្តូរទីលំនៅដែលបានចាប់ផ្តើមកាលពីដើមខែឧសភា។ នៅសប្តាហ៍ទីមួយនៃខែមិថុនា គ្រួសារស្ទើរតែទាំងអស់ត្រូវបានបង្ខំអោយចាកចេញ និងផ្លាស់ប្តូរទីលំនៅទៅកាន់ទីតាំងពីរនៅជាយក្រុងភ្នំពេញ។

### *ការបណ្តេញចេញ*

នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២006 អាជ្ញាធរបានចាប់ផ្តើមរុះរើ (កំទេច) ភូមិសំបុកចាបដោយមានជំនួយពីកងកំលាំងសន្តិសុខដែលប្រដាប់ដោយអាវុធ និងដំបងឆក់។ នៅមុនការបណ្តេញចេញនេះ អង្គការមិនមែនរដ្ឋាភិបាលបានស្នើអោយអាជ្ញាធរបង្ហាញពីផែនការរុះរើនិងតាំងទីលំនៅថ្មី និងធ្វើការពិនិត្យមើលលើសហគមន៍ដើម្បីកំណត់អំពីចំនួនពិតប្រាកដនៃគ្រួសារដែលទទួលផលប៉ះពាល់។ សំណើទាំងនេះត្រូវបានបដិសេធ។ អង្គការមិនមែនរដ្ឋាភិបាលបានចាប់ផ្តើមកិច្ចខិតខំរបស់ខ្លួនដើម្បីធ្វើការពិនិត្យមើលដោយឯករាជ្យមួយទាំងនៅមុនពេល និងកំឡុងពេលនៃការបណ្តេញចេញ ប៉ុន្តែកិច្ចខិតខំទាំងនេះត្រូវបានបញ្ឈប់ដោយអាជ្ញាធរ។

បន្ទាប់ពីការរុះរើផ្ទះ អ្នកជួលដែលពុំមានសិទ្ធិទទួលបានដីធ្លីនៅតំបន់ដែលត្រូវផ្លាស់ទៅនោះ បន្តស្នាក់នៅក្នុងកន្លែងនេះដោយគ្មានជំរក។ អង្គការមិនមែនរដ្ឋាភិបាលត្រូវបានអាជ្ញាធររារាំងមិនអោយផ្តល់ជំនួយមនុស្សធម៌បឋមដែលរួមមានសំពត់តង់ ហើយគ្រួសារទាំងនេះត្រូវបានបង្ខំចិត្តស្នាក់នៅលើគំនរកំទិចកំទីក្នុងសំលេងទ្រហឹងអឹងកង និងការបង្កអសន្តិសុខពីក្រុមរុះរើ។ ជាមួយនឹងការមកដល់នៃរដូវភ្លៀងនៅក្នុងប្រទេសកម្ពុជា ភ្លៀងព្យុះ និងការមានភក់បប៉ិចបប៉ាច់បន្ទាប់ពីភ្លៀងធ្លាក់ កាន់តែធ្វើអោយមានស្ថានភាពលំបាកខ្លាំងឡើងដល់អ្នកជួល។ បុគ្គលិកក្រុមហ៊ុនបានសង់របងនៅជុំវិញសហគមន៍ ដើម្បីបិទបាំងមិនអោយសាធារណជនមើលឃើញទៅខាងក្នុង។

នៅថ្ងៃទី៣១ ខែឧសភា កុប្បកម្មទ្រង់ទ្រាយធំមួយបានផ្ទុះឡើងនៅក្នុងភូមិសំបុកចាប បន្ទាប់ពីការបង្កគ្រោះថ្នាក់ដល់ក្មេងស្រីម្នាក់ និងស្ត្រីមានផ្ទៃពោះម្នាក់ដែលតាមការអោយដឹងគឺប្រព្រឹត្តឡើងដោយអ្នកយាម (ឆ្មាំ) ភូមិ។ អ្នកជួលបានបំផ្លាញការិយាល័យភូមិ និងរបងរបស់ក្រុមហ៊ុនដែលសង់ព័ទ្ធសហគមន៍។ ៦ថ្ងៃក្រោយមកសាលាក្រុងបានរៀបចំការរុះរើបណ្តេញដោយបង្ខំជាទ្រង់ទ្រាយធំចេញពីតំបន់នេះ។ នៅវេលាម៉ោង ៤ ព្រឹក កងកំលាំងប៉េអឹម និងកងកំលាំងរបស់សាលាក្រុងប្រមាណ ១.000 នាក់ បានមកប្រមូលផ្តុំគ្នានៅមុខភូមិសំបុកចាប។ កងកំលាងទាំងនេះសុទ្ធតែប្រដាប់ដោយអាវុធវែងខ្លី ដំបងឆក់ ប្រដាប់ការពារឧស្ម័ននិងឧបករណ៍ប្រឆាំងកុប្បកម្ម។ អ្នកកាសែត និងអ្នកតាមឃ្លាំមើលនៅក្នុងនិងនៅជិតៗតំបន់នោះត្រូវបានបណ្តេញចេញពីទីនោះភ្លាមៗដែរ។ ការបិទផ្លូវរបស់ប៉ូលីសធ្វើអោយអ្នកឃ្លាំមើលរបស់ NGO អ្នកសង្កេតការណ៍របស់ UN-OHCHR និងអ្នកកាសែតមិនអាចមើលឃើញព្រឹត្តិការណ៍

---

[១] តំបន់នេះត្រូវបានគេស្គាល់ផងដែរថាជា សហគមន៍បាសាក់ និងភូមិ ១៤។

[២] ទោះបីជាសាលាក្រុងបានប្រកាសថាខ្លួនបានបណ្តេញអ្នកភូមិសំបុកចាប តាងនាមអោយក្រុមហ៊ុនស្ួរ ស្រ៊ុន ក៏ដោយ ប៉ុន្តែទាំងសាលាក្រុង និងក្រុមហ៊ុន ស្ួរ ស្រ៊ុន មិនបានបង្ហាញឯកសារណាមួយស្តីពីសិទ្ធិកាន់កាប់ដីធ្លីរបស់ក្រុមហ៊ុននេះទេ។

នោះទេ ។ នៅវេលាម៉ោង ៦ ព្រឹក ការបណ្តេញចេញអ្នកដែលជួលផ្ទះនៅភូមិសំបុកចាបបានចាប់ផ្តើម ។ គ្រួសារទាំងអស់ត្រូវបានដាក់អោយជិះឡាន និងដឹកទៅកាន់ទីតាំងផ្លាស់ទីលំនៅមួយកន្លែង ។

អ្នកភូមិប្រមាណ ១៥០ គ្រួសារ បន្តរស់នៅក្នុងតំបន់បាសាក់ ( ក្រុម៧៨) ប្រហែលដោយសារមានឯកសារជាច្រើនបញ្ជាក់ពីផលប្រយោជន៍ជាកម្មសិទ្ធិនៅលើដីរបស់ពួកគេ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តីរបាយការណ៍ពេលថ្មីៗនេះបង្ហាញថាគ្រួសារទាំងនេះ កំពុងស្ថិតនៅក្នុងការគំរាមកំហែងពីការបង្ខំអោយចាកចេញដូចគ្នាដែរ ។

### ការចាប់ខ្លួន

នៅក្នុងការបណ្តេញ និងការផ្លាស់ទីលំនៅពីភូមិសំបុកចាបត្រូវបានកត់សំគាល់ដោយការចាប់ខ្លួនជាបន្តបន្ទាប់របស់អាជ្ញាធរ ។ នៅព្រឹកថ្ងៃទី៦ ខែមិថុនា ប៉ូលីសក្រុង និង ប៉េអឹម បានចាប់ខ្លួនឬឃាត់ខ្លួនប្រជាជនរហូតដល់ទៅ ៨ នាក់ ។ រយៈពេល ២ ថ្ងៃបន្ទាប់ពីការចាប់ខ្លួនសាលាក្រុងមិនបានផ្សព្វផ្សាយព័ត៌មានណាមួយអំពីឈ្មោះ និងកន្លែងឃាត់ខ្លួនអ្នកដែលត្រូវចាប់ខ្លួន ឬបង្ហាញពីការចោទប្រកាន់ក្នុងបទល្មើសអ្វីមួយចំពោះពួកគេនោះទេ ។ សំនួរដដែលៗរបស់មេធាវី និងអ្នកឃ្លាំមើលរបស់ UN ទាក់ទងនឹងអត្តសញ្ញាណ និងការឃាត់ខ្លួនអ្នកដែលត្រូវបានចាប់ខ្លួនទាំងនោះត្រូវបានឆ្លើយតបមកវិញដោយចំលើយគេចវេសឬការនៅស្ងៀមរបស់មន្ត្រីសាលាក្រុង[៣] ។

### ទីតាំងផ្លាស់ទីលំនៅថ្មី

បន្ទាប់ពីកើតមានការបណ្តេញចេញមកម្ចាស់ផ្ទះមួយចំនួនត្រូវបានផ្លាស់ទីលំនៅទៅកាន់ភូមិត្រពាំងក្រសាំង ( ខ័ណ្ឌ ដង្កោ) ដែលមានចំងាយប្រមាណ ២០ គម ពីទីក្រុង ។ គ្រួសារជាង ១.០០០ ត្រូវបានផ្តល់អោយនូវដីឡូតិ៍ ប៉ុន្តែមកដល់ចុងខែឧសភានេះ មានបង្គន់អនាម័យតែ ៣០ ប៉ុណ្ណោះ សំរាប់ប្រើប្រាស់ ។ មិនទាន់មានការរៀបចំប្រព័ន្ធអគ្គិសនី និងលូបង្ហូរទឹកសំអុយនៅឡើយទេ ហើយតំរូវការទឹកសំរាប់ជំរុំទាំងមូលត្រូវបានផ្តល់អោយដោយមានចំពួយទឹកតែមួយ ។ ផ្សារ និងសាលារៀនកំពុងសាងសង់តែនៅមិនទាន់ រួចស្រេចនៅឡើយទេ ។ កន្លែងជាច្រើននៅក្នុងទីតាំងនេះ ត្រូវលិចទឹកដោយ សារទាបជាងដីស្រែជុំវិញ ដែលធ្វើអោយពួកគេកាន់តែងាយទទួលរងនូវទឹកជំនន់ ។

អ្នកជួលត្រូវបានគេផ្លាស់ទីលំនៅទៅកាន់ភូមិអណ្តូងដែលមានចំងាយប្រមាណ ២០ គ.ម ដែរពីទីក្រុង ។ គ្រួសារជាង ១.០០០ កំពុងរស់នៅលើផ្ទៃដី១ហិកតា ។ ទីតាំងនេះគ្មាន ទឹកស្អាត អគ្គិសនី លូបង្ហូរទឹកសំអុយ ឬសាលារៀនទេ ហើយ អាជ្ញាធរ ក៏មិនទាន់បានកំណត់ដីឡូតិ៍នៅឡើយដែរ ។ មិនមានផែនការបែងចែកដីធ្លីត្រូវបានអនុវត្តនោះ ទេប្រជាជនត្រូវបានគេយកទៅទុកចោលនៅកន្លែងនោះបន្ទាប់ពីការផ្លាស់ទីលំនៅ ។ ការសាងសង់បង្គន់អនាម័យចំនួន ៥ កំពុងដំណើរការ ។

ដោយទីតាំងទាំងពីរមានទំហំមិនគ្រប់គ្រាន់ ស្ថិតនៅឆ្ងាយដាច់ស្រយ៉ាល កង្វះសេវាមូលដ្ឋាន និងភាពងាយលិចទឹក ដូច្នេះឱកាសសំរាប់ការមានកំរិតជីវភាពសមរម្យ គឺតិចតួចណាស់ ។ អាជ្ញាធរនៅមិនទាន់បានផ្សព្វផ្សាយពីដំណើរការដែលធានាដល់សិទ្ធិកាន់កាប់ដីធ្លីសំរាប់គ្រួសារដែលផ្លាស់ទីលំនៅទាំងនោះនៅឡើយទេ ។

## ការប្តេជ្ញាចិត្តចំពោះយុទ្ធសាស្ត្រចតុកោណផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងសន្ទស្សន៍តាមដានរួម

ភូមិសំបុកចាបបង្ហាញពីភាពបរាជ័យក្នុងការអនុវត្តន៍យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដែលកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា និងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសំរាប់ឆ្នាំ ២០០៦-២០១០ ។ ភាពមិនស្របគ្នារវាងគោលនយោបាយនិងការពិតជាការក្រើនរំលឹកមួយដែលតម្រូវអោយចាប់អារម្មណ៍ចំពោះការចាត់វិធានការជាបន្ទាន់នានា ទាមទារឱ្យមានភាពស្របគ្នារវាងគោលនយោបាយ និងការអនុវត្តន៍ ។

### អភិបាលកិច្ចល្អ

អភិបាលកិច្ចល្អត្រូវបានកំណត់ជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសូចនាករតាមដានរួមជាច្រើនសំរាប់ឆ្នាំ២០០៦ ។ យុទ្ធសាស្ត្រចតុកោណចែងថា "អភិបាលកិច្ចល្អតំរូវអោយមាននូវការចូលរួមយ៉ាងទូលំទូលាយការលើកកំពស់ការចែករំលែកពត៌មាន គណនេយ្យភាព តំលាភាព សមភាព ការមិនបោះបង់បុគ្គលណាម្នាក់ និងការប្រតិបត្តិតាមវិធាននៃច្បាប់[៤] " ហើយនាយករដ្ឋមន្ត្រីបានសន្យាកាល ពីខែមីនាថា "កំណែទំរង់រដ្ឋនៅគ្រប់កំរិតទាំងអស់នឹងត្រូវអនុវត្តដើម្បីអោយរដ្ឋាភិបាលមានការឆ្លើយតបទៅនឹងតម្រូវការនានាបានពេញលេញមានការការទទួលខុសត្រូវមានប្រសិទ្ធភាព មានតំលាភាព មានគណនេយ្យភាព និងភាពដែលអាចទស្សន៍ទាយបាននៅក្នុងការអនុវត្តន៍ការងាររបស់ខ្លួនដើម្បីបំរើតំរូវការរបស់ប្រជាពលរដ្ឋ[៥] " ។ ការសន្យានេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសន្ទស្សន៍តាមដានរួមលេខ ៤ ដែលស្នើអោយរដ្ឋាភិបាល "បង្កើតក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់ទៅលើលទ្ធភាពទទួល បានព័ត៌មាន" នៅក្នុងគោលបំណងនៃការបង្កើតតួនាទីច្បាស់លាស់ និងប្រព័ន្ធតុលាការដែល មានតំលាភាព[៦] ។

[៣] គិតមកដល់ថ្ងៃ ៦ ខែមិថុនា បុរស ៤ នាក់កំពុងជាប់ក្នុងការឃុំឃាំងនៅឡើយ

[៤] យុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា វាក្យខ័ណ្ឌ ២.១ ( ២០០៤)

[៥] សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងសុន្ទរកថាបើកកិច្ចប្រជុំ CG ភ្នំពេញ ២ មីនា ២០០៦

[៦] សន្ទស្សន៍តាមដានរួម សំរាប់កិច្ចប្រជុំ CG លើកទី ៨ 4(i) (2006)

ការបណ្តេញ និងការផ្លាស់ទីលំនៅថ្មីនៃភូមិសំបុកចាប បង្ហាញពីសញ្ញានៃការបរាជ័យនៅគ្រប់ទិដ្ឋភាពទាំងអស់នៃអភិបាលកិច្ចល្អ ដូចដែលបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ។

- សាលាក្រុងមិនយកចិត្តទុកដាក់នឹងសំណើសំរាប់ការអោយមានដំណើរការនៃការបណ្តេញចេញ និងការផ្លាស់ទីលំនៅដោយចំហរ និងមានតំលាភាព ។
- កិច្ចខិតខំដើម្បីពិនិត្យមើលគ្រួសារដែលទទួលផលប៉ះពាល់ និងដើម្បីផ្តល់ជំនួយមនុស្សធម៌បឋមត្រូវបានអាជ្ញាធរ ហាមឃាត់ ។
- អ្នកសង្កេតការណ៍របស់ UN អ្នកកាសែត និងអ្នកឃ្លាំមើលរបស់ NGO ត្រូវបានហាមឃាត់មិនអោយចូលទៅក្នុងភូមិសំបុកចាបនៅក្នុងកំឡុងពេលនៃការបណ្តេញចេញទ្រង់ទ្រាយធំកាលពីថ្ងៃទី ៦ ខែមិថុនា ។
- ដំណើរការនៃការតាំងទីលំនៅថ្មីត្រូវបានបង្កជាបញ្ហាឡើងដោយការចោទប្រកាន់អំពីអំពើពុករលួយ និងការបោកបន្លំ ដោយសារមនុស្សរបស់អាជ្ញាធរនៅក្នុងសហគមន៍ត្រូវបានគេផ្តល់អោយនូវដីជាច្រើនឡូតិ៍ ឯចំណែកអ្នកផ្សេងទៀតនៅតែមិនបានទទួលដី ។
- សាលាក្រុងមិនបានផ្សព្វផ្សាយជាសាធារណៈអំពីផែនការចុះបញ្ជីនិងផ្តល់ប័ណ្ណកម្មសិទ្ធិដល់គ្រួសារដែលផ្លាស់លំនៅថ្មី ។
- សាលាក្រុងមិនបានផ្សព្វផ្សាយជាសាធារណៈអំពីកម្មសិទ្ធិកាន់កាប់ដីរបស់ក្រុមហ៊ុន សួរ ស្រ៊ុន ឬព័ត៌មានណាមួយទាក់ទងនឹងកម្មសិទ្ធិកាន់កាប់ដីដែលជាមូលដ្ឋាននៃការបណ្តេញនេះ ។
- រយៈពេលពីរថ្ងៃ សាលាក្រុងបដិសេធមិនផ្សព្វផ្សាយព័ត៌មានណាមួយទាក់ទងនឹងការចាប់ខ្លួនប្រជាជនបន្ទាប់ពីការបណ្តេញនៅភូមិសំបុកចាប ។

## *ការកាត់បន្ថយភាពក្រីក្រ*

កាលពីខែមីនា នាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់ថា "រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋជាគោលបំណងស្នូលនៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាំងអស់របស់រដ្ឋាភិបាល" [៧] ។ ស្របតាមយុទ្ធសាស្ត្រចតុកោណ នាយករដ្ឋមន្ត្រីក៏គត់សំគាល់ថា NSDP តំរូវអោយរដ្ឋាភិបាល "ដាក់បញ្ចូលការកាត់បន្ថយភាពក្រីក្រ... ទៅក្នុងរាល់សកម្មភាពទាំងអស់" និង "ផ្តោតគោលដៅទៅលើប្រជាជននិងតំបន់ដែលត្រូវការបំផុតនិងទទួលការបំរើតិចតួច" [៨] ។ លោកបានសន្យាថា "នៅពេលនេះវាល្មមដល់ពេលហើយដែលធនធានទាំងអស់ចាប់ផ្តើមតំរង់ទិសអោយបានត្រឹមត្រូវ និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់ផលប្រយោជន៍ជាអតិបរិមាទៅដល់ជនដែលលំបាកវេទនា និងបាត់បង់សិទ្ធិសេរីភាពដើម្បីបញ្ចូលពួកគេទៅក្នុងចរន្តនៃសង្គមវិញ" [៩] ។ នាយកធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា លោក Ian Porter បានឯកភាពដោយកត់សំគាល់ថា "ផលប្រយោជន៍ចំបងនៃ (កំណើនរបស់ប្រទេសកម្ពុជាក្នុងរយៈពេល ១ ទសវត្សកន្លងមក) គឺប្រមូលផ្តុំយ៉ាងខ្លាំងទៅលើស្រទាប់អ្នកមាននៅទីក្រុងដែលបណ្តាលអោយមានកំណើនវិសមភាពយ៉ាងលឿនរវាងអ្នកមាន និងអ្នកក្រ" [១០] ។ សន្និស្សន៍តាមដានរួមលេខ ៨ ដាក់បញ្ចូលនូវរាល់ការគិតពិចារណាទាំងនេះ ដោយបានកំណត់នូវ "គោលនយោបាយរួមសំរាប់សុវត្ថិភាពសង្គម ដើម្បីធានាសន្តិសុខស្បៀង និង អាហារូបត្ថម្ភសំរាប់ក្រុមដែលងាយរងគ្រោះបំផុតរបស់ប្រជាជន" [១១] ។

សាលាក្រុងភ្នំពេញបានបញ្ជាក់អោយដឹងម្តងហើយម្តងទៀតថា យុទ្ធសាស្ត្រអភិវឌ្ឍន៍ក្រុងរបស់ខ្លួនសំដៅបិទបាំងជាជាងលុបបំបាត់ភាពក្រីក្រនៅទីក្រុង ។

- លោកអភិបាលក្រុង កែប ជុតិមា កត់សំគាល់ថា អ្នកភូមិសំបុកចាប "ធ្វើអោយខូចសោភ័ណភាពទីក្រុងរបស់យើង" ហើយពួកគេគួរតែទៅតាំងទីលំនៅថ្មីនៅក្នុងទីតាំងដែលមិនបានបញ្ជាក់ [១២] ។
- ក្រោយពីការរុះរើផ្ទះសំបែង អ្នកជួលផ្ទះទាំងអស់ត្រូវរស់នៅដោយគ្មានទីជំរក ឬទទួលបានសេវាមូលដ្ឋាន ។ NGOs ត្រូវបានបដិសេធមិនអោយផ្តល់ជំនួយមនុស្សធម៌ដែលរួមមានក្រណាត់តង់ទៅដល់អ្នកជួលផ្ទះទាំងនោះ ។
- ដោយមិនធ្វើការស៊ើបអង្កេតមើលរបាយការណ៍នៃអំពើហិង្សាដែលអាជ្ញាធរបានធ្វើមកលើអ្នកភូមិដែលបានកើតឡើងនៅមុនពេលមានកុប្បកម្មនៅក្នុងសហគមន៍ សាលាក្រុងបែរជាមើលឃើញពីភាពត្រឹមត្រូវក្នុងការចាប់ខ្លួន ឬឃុំខ្លួនអ្នកភូមិប្រមាណ ៨ នាក់ ដែលជាប់ពាក់ព័ន្ធនឹងកុបកម្ម ។
- ទីតាំងសំរាប់ការតាំងទីលំនៅថ្មីនៅត្រពាំងក្រសាំងមានចំងាយ ២០ គ.ម. ពីទីក្រុង ហើយមានចំពួយទឹកមួយ និងបង្គន់អនាម័យចំនួន ៣០ សំរាប់ជាង ១០០០គ្រួសារ ។ នៅទីនោះនៅខ្វះខាតប្រព័ន្ធលូទឹកសំអុយ អគ្គិសនី និងមណ្ឌលសុខភាព ។

---

[៧] នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងសុន្ទរកថាបើកកិច្ចប្រជុំ CG លើកទី ៨ ភ្នំពេញ, ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៦

[៨] Id.

[៩] សាររបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន NSDP ២០០៦-២០១០

[១០] Ian C. Porter សុន្ទរកថាបិទនៅក្នុងកិច្ចប្រជុំ CG លើកទី៨ ភ្នំពេញ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៦

[១១] សន្និស្សន៍តាមដានត្រួតពិនិត្យរួមសំរាប់កិច្ចប្រជុំក្រុមពិគ្រោះយោបល់លើកទី ៨ (v) (2006)

[១២] កាសែត The Cambodia Daily, អ្នកភូមិទន្លេបាសាក់ ត្រូវបានបង្ខំអោយចាកចេញ នៅសប្តាហ៍ក្រោយ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៦

- ទីតាំងសំរាប់តាំងទីលំនៅថ្មីនៅភូមិអណ្តូង មានចំងាយ ២០ គ.ម ពីទីក្រុង ហើយមិនមានសេវាមូលដ្ឋានអ្វីសោះ ។ គ្មានទឹកបង្គន់អនាម័យ គ្លីនិក ឬសាលារៀនឡើយ ។ ការកសាងបង្គន់អនាម័យចំនួន ៥ កំពុងដំណើរការសំរាប់គ្រួសារជាង ១០០០ នៅលើទីតាំង ។
- មិនមានការផ្តល់ជំនួយសំរាប់រយៈពេលវែងចំពោះគ្រួសារដែលមកតាំងទីលំនៅថ្មីឡើយ ហើយអាជ្ញាធរគ្រាន់តែចែកចាយម្ហូបអាហារតិចតួចទៅដល់គ្រួសារមួយចំនួនប៉ុណ្ណោះ ក្នុងលក្ខណៈជាបណ្តោះអាសន្ន ។

## *ជំលោះដីធ្លី និងអសន្តិសុខកម្មសិទ្ធិដី*

ជាចុងក្រោយ ដំណើរការបណ្តេញអ្នកភូមិសំបុកចាប សំដែងអោយឃើញនូវបរាជ័យរបស់រាជរដ្ឋាភិបាលក្នុងការធ្វើអោយមានការវិវត្តន៍ឆ្ពោះទៅរកការកាត់បន្ថយអសន្តិសុខកម្មសិទ្ធិដីធ្លីដែលតាមការកត់សំគាល់របស់គណៈប្រតិភូអាល្លឺម៉ង់ កាលពីខែមីនា គឺជា "ឧបសគ្គចំបងសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមនៅប្រទេសកម្ពុជា ហើយពិតជាកត្តាដែលនាំទៅរកកំណើនវិសមភាព"[១៣]។ ដើម្បីដោះស្រាយកង្វល់អំពីកម្មសិទ្ធិដីធ្លីកាលពីខែមីនា នាយករដ្ឋមន្ត្រីបានសន្យាថានឹង "ខិតខំធ្វើការអោយបានកាន់តែខ្លាំងក្លាដើម្បីអោយប្រជាជនក្រីក្រកម្ពុជាទទួលបានកម្មសិទ្ធិដីធ្លីដែលមានសុវត្ថិភាព"[១៤]។ បើទោះបីជា JMIs 2006 ដែលដោះស្រាយបញ្ហាទាំងនេះ បានផ្តោតគោលដៅលើសហគមន៍នៅតំបន់ជនបទក៏ដោយ ក៏ការគិតពិចារណាដែលបានធ្វើឡើងនៅក្នុងការកសាងគោលដៅ CG នេះគួរអនុវត្តចំពោះសហគមន៍ ក្រីក្របំផុតនៅក្នុងទីក្រុងរបស់យើងផងដែរ ។

ការបណ្តេញអ្នកភូមិសំបុកចាបចេញ និងការតាំងទីលំនៅថ្មីនេះ បង្ហាញយ៉ាងច្បាស់នូវកំណើនវិសមភាពដែលបណ្តាល មកពីអសន្តិសុខកម្មសិទ្ធិដីធ្លី និងលទ្ធផលនៃជំលោះដីធ្លីដែលគេបានយកក្រុមហ៊ុនដ៏ធំមួយមកធ្វើការការប្រកួតប្រជែង ជាមួយសហគមន៍ក្រីក្រ ។

- គ្រួសារប្រមាណ ២០០០ ត្រូវបានបង្ខំអោយចាកចេញ និងតាំងទីលំនៅថ្មីនៅក្រៅក្រុង
- ផែនការចុះបញ្ជីដីធ្លី និងផ្តល់ប័ណ្ណកម្មសិទ្ធិសំរាប់គ្រួសារទាំងអស់ដែលតាំងទីលំនៅថ្មីនៅត្រពាំងក្រសាំងមិនទាន់ត្រូវបានផ្សព្វផ្សាយអោយដឹងឡើយ ។
- ផែនការចុះបញ្ជីដីធ្លី និងផ្តល់ប័ណ្ណកម្មសិទ្ធិសំរាប់គ្រួសារទាំងអស់ដែលតាំងទីលំនៅថ្មី នៅភូមិអណ្តូងមិនទាន់ត្រូវបានផ្សព្វផ្សាយអោយដឹងនៅឡើយ ។ របាយការណ៍ជាច្រើនបង្ហាញថា មានប្រជាពលរដ្ឋត្រឹមប្រមាណ ៤០០ គ្រួសារប៉ុណ្ណោះដែលអាចមានសិទ្ធិ ចំពោះកម្មសិទ្ធិដីធ្លីឯប្រជាពលរដ្ឋប្រមាណជា ៥០០ គ្រួសារផ្សេងទៀតអាចនឹងត្រូវរងគ្រោះចំពោះការបង្ខំអោយចាកចេញជាថ្មីទៀត ។
- ទាំងក្រុមហ៊ុន សួរ ស្រ៊ុន និងសាលាក្រុងភ្នំពេញមិនបានផ្សព្វផ្សាយអោយដឹងនូវឯកសារច្បាប់ដែលជាមូលដ្ឋានសំរាប់ការបណ្តេញចេញនេះឡើយ ។
- របាយការណ៍ជាច្រើនបង្ហាញថា សហគមន៍ដែលនៅជិតៗនោះ[១៥] នៅក្នុងតំបន់ទន្លេបាសាក់ ត្រូវបានរងការគំរាមកំហែងអោយចាកចេញ បើទោះបីជាមានឯកសារជាច្រើនបញ្ជាក់ពីផលប្រយោជន៍ជាកម្មសិទ្ធិនៅលើដីក៏ដោយ ។
- វានៅមិនទាន់ច្បាស់ថាហេតុអ្វីបានជាតុលាការបានចេញដីកាពាក់ព័ន្ធនឹងជំលោះនេះនៅពេលដែលស្ថានភាពដីបញ្ជាក់ថា គណៈកម្មការសុរិយោដីត្រូវមានយុត្តាធិការ (សមត្ថកិច្ច) លើបញ្ហានេះ ។

## អនុសាសន៍

សរុបមក *ភូមិសំបុកចាប* តំណាងអោយការបរាជ័យក្នុងការគោរពទៅតាមគុណតំលៃជាមូលដ្ឋានបំផុតនៃការកាត់បន្ថយភាពក្រីក្រ និងយុទ្ធសាស្ត្រចតុកោណ ។ ជាជាងប្តេជ្ញាចិត្តដោយខ្លួនឯងដើម្បីជួយដល់អ្នកក្រប្រកបដោយតម្លាភាព និងសមធម៌ សាលាក្រុងហាក់ ដូចជាកំពុងធ្វើសកម្មភាពបំរើអោយតែផលប្រយោជន៍ក្រុមហ៊ុនដែលមានអំណាចប៉ុណ្ណោះ ។ NGOs សូមគោរពស្នើសុំអោយម្ចាស់ជំនួយលើកករណី *ភូមិសំបុកចាប* ទៅដល់រាជរដ្ឋាភិបាលកម្ពុជា និងស្នើសុំអោយរដ្ឋាភិបាលចាត់វិធានការ និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ តំលាភាព និងសន្តិសុខកម្មសិទ្ធិដីធ្លីនៅទីក្រុងភ្នំពេញ តាមរយៈការអនុវត្តន៍ជាបន្ទាន់នូវអនុសាសន៍ដូចខាងក្រោមនេះ :

- ផ្តល់ជំនួយសង្គ្រោះមនុស្សធម៌ជាបន្ទាន់ និងសេវាមូលដ្ឋានទៅដល់គ្រួសារដែលត្រូវតាំងទីលំនៅថ្មីនៅត្រពាំងក្រសាំង និងអណ្តូងដែលរួមមានសំភារៈសំរាប់កសាងទីជំរក ទឹកប្រើប្រាស់ សន្តិសុខស្បៀងសំរាប់រយៈពេល៦ខែ ប្រព័ន្ធលូ ទឹកសំអុយ និងបង្គន់អនាម័យសាលារៀន និងគ្លីនិកសុខភាព ។ គួរផ្តោតការយកចិត្តទុកដាក់ ពិសេសដល់ស្ត្រីមានផ្ទៃពោះ និងកុមារ ។

---

[១៣] សេចក្តីថ្លែងការណ៍រួមរបស់ម្ចាស់ជំនួយស្តីពីការគ្រប់គ្រងធនធានធម្មជាតិ ដីធ្លី និងកសិកម្ម នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី ៨ ថ្ងៃទី២-៣ ខែមីនា ឆ្នាំ២០០៦ ។

[១៤] នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងសុន្ទរកថាបើកកិច្ចប្រជុំពិគ្រោះយោបល់លើកទី ៨ ភ្នំពេញ, ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៦

[១៥] ឧទាហរណ៍ ក្រុម ៧៨

- ផ្តល់សុវត្ថិភាពនៃការកាន់កាប់ដីធ្លី ទៅដល់គ្រួសារដែលត្រូវតាំងទីលំនៅថ្មី តាមរយៈការផ្តល់កម្មសិទ្ធិ និងចុះបញ្ជីគ្រួសារទាំងអស់ជាកម្មសិទ្ធិករដីធ្លី ។ ធានាអោយមានតម្លាភាពនៅក្នុងដំណើរការបែងចែកដី ដើម្បីអោយគ្រួសារដែលមានសិទ្ធិពិតប្រាកដទទួលផលប្រយោជន៍ ។
- ផ្សព្វផ្សាយជាសាធារណៈនូវឯកសារច្បាប់របស់ក្រុមហ៊ុន សួរ ស្រ៊ុន ដែលជាមូលដ្ឋានក្នុងការទាមទារយកភូមិសំបុកចាប ។
- ដោះលែង និងលើកលែងការចោទប្រកាន់ចំពោះជនដែលជាប់ឃុំទាំងអស់ពាក់ព័ន្ធនឹងការបង្ខំអោយចាកចេញពីភូមិសំបុកចាប និងរាល់ការបំភិតបំភ័យបន្ថែមទៀត ឬការរើសអើងចំពោះបុគ្គលទាំងនេះ ។
- បញ្ឈប់ការបំភិតបំភ័យចំពោះគ្រួសារដែលនៅសេសសល់ នៅក្នុងតំបន់ទន្លេបាសាក់ ដែលរួមមានក្រុម ៧៨ ផងដែរ ។
- បញ្ឈប់ការប្រើប្រាស់កំលាំង និងការបំភិតបំភ័យក្នុងការបង្ខំអោយចាកចេញពីភ្នំពេញ ។
- អនុញ្ញាតអោយ NGOs ដែលឯករាជ្យបានចូលទៅដល់ទាំងទីតាំងបង្ខំអោយចាកចេញ និងទីតាំងទីលំនៅថ្មី ដើម្បីផ្តល់ជំនួយមនុស្សធម៌ ។
- ធានាអោយសាលាក្រុងភ្នំពេញគោរពទៅតាមសេចក្តីថ្លែងការណ៍អំពីគោលការណ៍នៃការអនុវត្តន៍ដ៏ល្អបំផុតសំរាប់ផ្ទះសំបែង និងការអភិវឌ្ឍន៍សំរាប់អ្នកក្រីក្រនៅទីក្រុងភ្នំពេញ ។

កាលបើគ្មានវិធានការទេ វាជាគ្រោះថ្នាក់មួយដែលរាជធានីនៃប្រទេសកម្ពុជា នឹងក្លាយជាទីក្រុងដែលមានការបែងចែកក្នុងពេលឆាប់ៗនេះ រវាងអ្នកមាន និងអ្នកក្រដូចដែលតំណាងពិសេសរបស់អង្គការសហប្រជាជាតិ Miloon Kothari បានព្រមាន ។[១] នៅពេលដែលមន្ត្រីរដ្ឋាភិបាល និងម្ចាស់ជំនួយជួបប្រជុំគ្នា ដើម្បីពិភាក្សាអំពីវឌ្ឍនភាពលើ JMIs ឆ្នាំ២០០៦ NGOs សង្ឃឹមថាវិធានការទាំងឡាយនឹងត្រូវបានធ្វើឡើងដើម្បី *សំរេចអោយបាន* នូវគោលការណ៍អភិបាលកិច្ចល្អនៅទីក្រុងភ្នំពេញ និងកាត់បន្ថយភាពក្រីក្រនៅរាជធានីប្រកបដោយ *ប្រសិទ្ធភាព* ។ ការពិភាក្សាអំពីករណី *ភូមិសំបុកចាប* និងការអនុវត្តន៍នូវអនុសាសន៍ដូចបានលើកឡើងខាងលើ នឹងជាជំហានដ៏សំខាន់ក្នុងការសំរេចបាននូវគោលដៅទាំងនេះ ។



កងកំលាំងប្រដាប់អាវុធត្រៀមបណ្តេញអ្នកស្រុកចេញពីសហគមន៍បាសាក់ (សំបុកចាប)



អ្នកស្រុករៀបចំដឹកជញ្ជូនសំភារៈដាក់លើរថយន្តទៅកាន់ទីតាំងលំនៅថ្មី

[១១] សូមមើលកាសែត The Cambodia Daily, *មន្ត្រីអង្គការសហប្រជាជាតិលើកប្រកាសសញ្ញាអាសន្ន ជុំវិញបញ្ហាទន្លេបាសាក់* ថ្ងៃទី៣-៤ ខែ មិថុនា ឆ្នាំ ២០០៦

# បញ្ហានៅក្នុងច្បាប់ថវិកាជាតិសំរាប់កាត់បន្ថយភាពក្រីក្រ

**ច្បាប់ស្តីពីថវិកាជាតិ** គឺជាឯកសារស្តីអំពីផែនការចំណូល និងចំណាយសំរាប់រយៈពេលកំណត់មួយដែលជាទូទៅ និងក្នុងករណីកម្ពុជាគឺសំរាប់រយៈពេលមួយឆ្នាំ ។ អត្ថបទនេះនឹងពិនិត្យមើលទៅលើតែផ្នែកមួយរបស់ថវិកាជាតិប៉ុណ្ណោះ គឺផ្នែកចំណាយ ។ *ចំណាយចរន្ត* គឺជាចំណាយទៅលើទំនិញ និងសេវាកម្មដែលត្រូវការចាំបាច់នៅក្នុងឆ្នាំដើម្បីទទួលបាននូវការបំរើសេវាកម្មដូចជា តំលៃពលកម្ម ប្រាក់បៀវត្ស និង ប្រាក់សោធននិវត្តន៍ ។ ចំណាចតូចតាចទៅលើគ្រឿងបរិក្ខារដែលតិចជាងតំលៃកំណត់ជាក់លាក់ណាមួយនោះ ក៏ត្រូវបានចាត់ចូលជាចំណាយចរន្តដែរ ។ *ចំណាយមូលធន* គឺការចំណាយទៅលើអចលនវត្ថុ ឧទាហរណ៍ ទ្រព្យសម្បត្តិដែលត្រូវបានប្រើប្រាស់ជាប្រចាំក្នុងដំណើរការផលិតកម្មហើយមានអាយុកាលប្រើប្រាស់លើសពីមួយឆ្នាំ ។ ចំណាយមូលធន រាប់បញ្ចូលទាំងការសាងសង់ ការជួសជុលជាដុំកំភួននៃអាគារ និងចំណាយក្នុងការទិញ រឺក៏ការផ្លាស់ប្តូរបរិក្ខារថ្មី ។ ក្នុងការប្រៀបធៀបតំរោងថវិការបស់រដ្ឋាភិបាលសំរាប់ឆ្នាំ២០០៤ ២០០៥ និង ២០០៦ ទិន្នន័យចាំបាច់ត្រូវតែកែតំរូវជាមួយនឹងអត្រាអតិផរណា ព្រោះថាតំលៃទំនិញច្រើនតែកើនឡើងគ្រប់ពេល ។ នៅពេលដែលការកែតំរូវទៅតាមអត្រាអតិផរណាបានធ្វើត្រឹមត្រូវហើយទិន្នន័យរបស់ឆ្នាំខុសៗគ្នាអាចយកមកប្រៀបធៀបគ្នាបាន ហើយយើងក៏អាចវិភាគការប្រែប្រួលក្នុងចំណាយពិតប្រាកដបានដែរ ។

ផែនការថវិកាជាតិគឺជាឧបករណ៍ដ៏សំខាន់បំផុតសំរាប់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកែប្រែគោលនយោបាយអោយទៅជាសកម្មភាពដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ចតាមរយៈការបែងចែក និងការផ្តល់នូវធនធានសាធារណៈ ។ តែទោះជាយ៉ាងណាក៏ដោយ ដូចដែលអ្នកនឹងឃើញក្នុងអត្ថបទនេះផែនការថវិកាជាតិរបស់កម្ពុជានៅមានចំនុចជាច្រើនដែលត្រូវកែលំអរដើម្បីអោយផែនការថវិកាជាតិនេះអាចដើរតួនាទីខាងលើនេះបាន ។ បញ្ហាសំខាន់ៗដែលត្រូវដោះស្រាយនៅក្នុងផែនការថវិកាឆ្នាំ២០០៧ មានៈ

- បង្កើនការយកទុកដាក់ទៅលើចំណែក "ដើម្បីជនក្រីក្រ"
- ការអនុវត្តន៍ផែនការថវិកាអោយបានត្រឹមត្រូវតាមផែនការ
- ធ្វើផែនការថវិកាឆ្នាំ២០០៧ ត្រូវស្របទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ និងផ្តល់ការវិនិយោគផ្នែកមូលធនដើម្បីជាប្រយោជន៍ដល់ពលរដ្ឋក្រីក្រនៅតាមជនបទ ។

ប្រជាពលរដ្ឋមានសិទ្ធិដឹងឮអំពីប្រភពនៃធនធាន និងការចំណាយរបស់រដ្ឋាភិបាល ។ នាពេលបច្ចុប្បន្ននេះ ពត៌មានអំពីថវិកាជាតិយើងអាចរកបានតិចតួចណាស់នេះជាឧបសគ្គយ៉ាងធ្ងន់ធ្ងរសំរាប់សង្គមស៊ីវិលក្នុងការចូលរួមចំណែកក្នុងបញ្ហានេះ ។ ក្រៅពីអនុសាសន៍បីចំនុចដែលបានរៀបរាប់ខាងលើ អនុសាសន៍ទី ៤ គឺធ្វើឱ្យពត៌មានអំពីថវិកានេះមានសំរាប់សាធារណៈជនទូទៅដោយរួមបញ្ចូលទាំងពត៌មានលំអិតអំពីៈ

- ថវិកាមូលធនសំរាប់ក្រសួង ស្ថាប័នចំណាយ រឺកម្មវិធីនីមួយៗ
- ចំណែកនៃចំណាយចរន្តដែលចាយទៅលើសេវាកម្ម និងសកម្មភាពដែលផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់ជនក្រីក្រ (ដូចជាប្រាក់បៀវត្សសំរាប់គ្រូបង្រៀន) និងចំណាយផ្សេងៗដែលពាក់ព័ន្ធ (ដូចជារដ្ឋបាលហិរញ្ញវត្ថុ) និង
- ចំនួនចំនួនសាច់ប្រាក់ដែលបានផ្តល់អោយក្រសួង ខេត្ត ក្រុង និងក្រុមប្រឹក្សាឃុំប្រចាំខែនីមួយៗ

## កំរិតនៃចំណែកដែលជាចំណែក "ដើម្បីជនក្រីក្រ" របស់ថវិកាជាតិឆ្នាំ ២០០៤-២០០៥

និយមន័យជាក់លាក់អំពីថាចំណាយបែបណានៅក្នុងផែនការថវិកាដែលគេចាត់ទុកថា "ដើម្បីជនក្រីក្រ" នោះទេ ប៉ុន្តែមានការយល់ ជារួមមួយថាចំណាយទាំងឡាយណាដែលធ្វើអោយមានការរីកចំរើនកសិកម្មខ្នាតតូចលើកកំពស់សេវាថែទាំសុខភាពជាមូលដ្ឋានគាំទ្រការអប់រំថ្នាក់បឋមសិក្សា និងអនុវិទ្យាល័យលើកកំពស់ការទទួលបាននូវទឹកស្អាត និងអានាម័យស្ថិតនៅក្នុងប្រភេទចំណាយដែលហៅថា "ដើម្បីជនក្រីក្រ" នេះ ។ ចំណាយផ្សេងៗទោះជាមានសារៈសំខាន់ក៏ដោយ ក៏មិនគួរចាត់ទុកថាជាចំណាយ "ដើម្បីជនក្រីក្រ" ដែរ ព្រោះវាធ្វើអោយមានភាពមិនច្បាស់លាស់ក្នុងការវាស់វែងប្រសិទ្ធភាពនៃអន្តរាគមន៍របស់រដ្ឋាភិបាល ។

ជាអកុសល ពត៌មានលំអិតអំពីចំណាយទៅលើសេវាកម្ម និងសកម្មភាពដែលផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់ជនរដ្ឋក្រីក្រនោះមិនអាចរកបាននៅឡើយ តែទោះជាយ៉ាងណា យើងអាចរកបាននូវពត៌មានអំពីថវិការ និងការចំណាយរបស់រដ្ឋាភិបាលសំរាប់វិស័យនីមួយៗ ។ តារាងខាងក្រោមនេះបង្ហាញនូវចំណែកនៃចំណាយចរន្តពិត[១៧] របស់រដ្ឋាភិបាលសំរាប់ក្រសួងដែលជាចំណាយស្ថិតក្នុងប្រភេទចំណាយ "ដើម្បី ជនក្រីក្រ" ។ តារាងទី១ ធ្វើការសង្ខេបទិន្នន័យអំពីថវិកាដែលបានមកពី ឧបសម្ព័ន្ធទី១ ហើយបង្ហាញឱ្យឃើញថានៅក្នុងរយៈពេលបីឆ្នាំកន្លងទៅនេះ ចំណែក

---

[១៧] *២០០៦ ត្រូវបានប្រើជាឆ្នាំគោលសំរាប់ការគណនាចំនួនពិតនៃថវិករ និងការបែងចែកសំរាប់ឆ្នាំ២០០៤ និង២០០៥ ។ តួរលេខអំពីអតិផរណាសំរាប់ឆ្នាំ២០០៤ និង ២០០៥ មាននៅក្នុងឧបសម្ព័ន្ធទី១ ។*

នៃចំណាយចរន្តពិតក្នុងច្បាប់ថវិកាជាតិ ដែលរួមចំណែកទៅក្នុងវិស័យ ដែលគេសន្មត់ថាមានរួមបញ្ចូលនូវសកម្មភាព "ដើម្បីជនក្រីក្រ" បានធ្លាក់ចុះពី ៤១.១% នៅឆ្នាំ២០០៤ មកនៅត្រឹម ៣៨.៨% នៅឆ្នាំ២០០៦ ។ ចំណាយជាក់ស្តែងនៅក្នុងវិស័យ "ដើម្បីជនក្រីក្រ" ទាំងនេះក៏ត្រូវបានកាត់បន្ថយដែរ ដូចដែលបានបង្ហាញនៅក្នុងទិន្នន័យអំពីការអនុវត្តន៍ថវិកា ពីឆ្នាំ២០០៤ ទៅ ២០០៥[១៨] ។

**តារាងទី១:** ចំណែកនៃការចំណាយ "ដើម្បីជនក្រីក្រ" នៅក្នុងចំណាយចរន្តឆ្នាំ ២០០៤ និង២០០៥

| | គំរោងថវិការ ២០០៤ | គំរោងថវិការ ២០០៥ | គំរោងថវិការ ២០០៦ | ការអនុវត្តន៍២ ០០៤ | ការអនុវត្តន៍២ ០០៥ |
|---|---|---|---|---|---|
| ចំណាចរន្តសរុប (I+II+III+IV+V) | ១០០% | ១០០% | ១០០% | ៩៧% | ១០០% |
| I. រដ្ឋបាលទូទៅ | ១៤.៥% | ១៤.៦% | ១៤.៦% | ១៧.៣% | ១៨.១% |
| II. ការពារ និងសន្តិសុខ | ២២.៩% | ២២.៨% | ២០.២% | ២៤.២% | ២២.៩% |
| III. រដ្ឋបាលសង្គម | ៣៨.៦% | ៣៧.៨% | ៣៦.២% | ៣៨.៥% | ៣៦.៦% |
| *១១. ពតិមាន* | *0.៧%* | *0.៧%* | *0.៧%* | *0.៧%* | *0.៧%* |
| *១២. សុខភាពសាធារណ:* | *១២.0%* | *១២.0%* | *១០.៨%* | *១១.0%* | *១១.៤%* |
| *១៦. អប់រំយុវជន និងកីឡា* | *១៨.៨%* | *១៨.៥%* | *១៨.៣%* | *១៨.៧%* | *១៧.៨%* |
| *១៨. វប្បធម៌ និងវិចិត្រសិល្បៈ* | *0.៨%* | *0.៧%* | *0.៦%* | *0.៧%* | *0.៧%* |
| *១៩. បរិស្ថាន* | *0.៥%* | *0.៤%* | *0.៤%* | *0.៤%* | *0.៤%* |
| *២១. សង្គមកិច្ច ការងារ និងយុវនីតិសម្បទា* | *១.៨%* | *៤.៧%* | *៤.៦%* | *១.៩%* | *៤.៨%* |
| *២៣. ធម្មការ និងសាសនា* | *0.២%* | *0.២%* | *0.២%* | *0.២%* | *0.២%* |
| *២៤. កិច្ចការនារី និងអតីតយុទ្ធជន* | *៣.៨%* | *0.៦%* | *0.៦%* | *៤.៩%* | *0.៥%* |
| IV. វិស័យសេដ្ឋកិច្ច | ១០.៦% | ១០.១% | ៩.៦% | ៨.៧% | ៩.១% |
| *0៥.៣. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល* | *0.៥%* | *0.៤%* | *0.៤%* | *0.៣%* | *0.៤%* |
| *១៣. ឧស្សាហកម្ម រ៉ែ និងថាមពល* | *0.៤%* | *0.៤%* | *0.៤%* | *0.៤%* | *0.៤%* |
| *១៥. ពាណិជ្ជកម្ម* | *១.0%* | *0.៩%* | *0.៩%* | *0.៧%* | *0.៧%* |
| *១៧. កសិកម្មព្រៃឈើ និងជលផល* | *២.៥%* | *២.៥%* | *២.៤%* | *២.២%* | *២.៤%* |
| *២០. អភិវឌ្ឍជនបទ* | *១.២%* | *១.២%* | *១.៤%* | *១.0%* | *១.១%* |
| *២២. ប្រៃសណីយ៍ និងទូរគមនាគមន៍* | *២.១%* | *១.៩%* | *១.៤%* | *១.៤%* | *១.៦%* |
| *២៥. សាធារណការ និងដឹកជញ្ជូន* | *0.៨%* | *0.៨%* | *0.៨%* | *0.៧%* | *0.៧%* |
| *២៧. ទេសចរណ៍* | *0.៨%* | *0.៧%* | *0.៧%* | *0.៧%* | *0.៧%* |
| *២៨. ដែនដី នគរូបនីយកម្ម និងសំណង់* | *0.៤%* | *0.៤%* | *0.៥%* | *0.៤%* | *0.៤%* |
| *២៩. ធនធានទឹក និងឧតុនិយម* | *0.៨%* | *0.៨%* | *0.៨%* | *0.៨%* | *0.៧%* |
| V. ផ្សេងៗ | ១៣.៤% | ១៤.៧% | ១៩.៣% | ៨.៤% | ១៣.៣% |
| ចំណែក "ដើម្បីជនក្រីក្រ" សរុប | ៤១.១% | ៤០.៣% | ៣៨.៨% | ៤០.៤% | ៣៨.៨% |

*គណនាចេញពីឧបសម្ព័ន្ធទី១ (តារាងទី២) ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

## ការអនុវត្តន៍គំរោងថវិកាអោយបានត្រឹមត្រូវតាមផែនការកំណត់

ចំណាយទៅលើវិស័យសុខភាព និងវិស័យអប់រំមានចំនួន ៧៥% នៃចំណាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រ ត្រូវនឹង ២៥% នៃថវិការសរុប ។ ដូចដែលមាននៅក្នុងតារាងទី ២ ខាងក្រោមនេះ ការអនុវត្តន៍ថវិកាជាតិជារួមគឺល្អ ព្រោះថា ៩៥% នៃថវិកាដែលបានបែងចែកអោយវិស័យសុខាភិបាល និងអប់រំត្រូវបានបញ្ចេញជាសាច់ប្រាក់ ។

**តារាងទី២:** គំរោងថវិការ និងការបញ្ចេញសាចលប្រាក់សំរាប់វិស័យសុខភាព និងវិស័យអប់រំ ឆ្នាំ ២០០៥

| ក្រសួង | ច្បាប់ថវិការ | សាច់ប្រាក់ដែលបាន បញ្ចេញ | ចំណែក | សាច់ប្រាក់ផ្តល់អោយជាមុនប្រចាំខែ |
|---|---|---|---|---|
| ១២. សុខាភិបាល | ២៣៩ | ២២៥ | ៩៤.0% | ១៩.៩ |
| ១៦. អប់រំយុវជន និងកីឡា | ៣៦៧ | ៣៥១ | ៩៥.៦% | ៣០.៦ |

*គណនាចេញពី ឧបសម្ព័ន្ធទី ១ (តារាងទី២) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

---

[១៨] *ការវិភាគដូចគ្នាសំរាប់ថវិកាមូលធនអាចបន្ថែមនូវតំលៃនៃពត៌មានដែលមាននៅក្នុងតារាងទី១ ប៉ុន្តែជាអកុសល ពត៌មានលំអិតអំពីផែនការ និងចំណាយពិតនៃថវិកាមូលធនមិនអាចរកបាន*

ទោះជាការផ្តល់ប្រាក់ជារួមមានលក្ខណៈល្អក៏ដោយបញ្ហាទាក់ទៅនឹងពេលវេលាក្នុងការបញ្ចេញសាច់ប្រាក់តាមការបែងចែកក្នុងគំរោងថវិកាត្រូវការដំណោះស្រាយជាបន្ទាន់ ។ ការប្រែប្រួលក្នុងការបែងចែកថវិកានៅក្នុងឆ្នាំ២០០៥ ត្រូវបានបង្ហាញអោយឃើញនៅក្នុងរូបភាពទី១ ខាងក្រោមនេះ ។ ចំណាយនៅចុងឆ្នាំ ( ថវិការដូវភ្លៀង) មានចំនួនជិត ១០ ដងនៃថវិកានៅដើមឆ្នាំ ( ថវិការដូវប្រាំង) ។ ការបញ្ចេញសាច់ប្រាក់ឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ច្បាស់ជានឹងជួយធ្វើអោយការផ្តល់សេវាក្នុងវិស័យសុខភាព និងវិស័យអប់រំ ព្រោះវានឹងធ្វើអោយមានការរៀបចំផែនការប្រសើរជាងមុននៅថ្នាក់មូលដ្ឋានជំរុញ និងលើកទឹកចិត្តបុគ្គលិកក្នុងការអនុវត្តន៍ការងារ និងកាត់បន្ថយមូលហេតុមួយនៃអំពើពុករលួយ ។

**រូបភាពទី១:** ការបញ្ចេញជាសាច់ប្រាក់ប្រចាំខែសំរាប់វិស័យសុខាភិបាល និងវិស័យអប់រំឆ្នាំ២០០៥




*ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឆ្នាំ២០០៥*

## ការផ្គូរផ្គងគំរោងថវិកាឆ្នាំ២០០៦ ទៅនឹងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងកម្មវិធីវិនិយោគសាធារណៈ

ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិដែលនឹងត្រូវយកមកអនុវត្តតាមរយៈគំរោងថវិកាជាតិ និងកម្មវិធីវិនិយោគសាធារណៈសង្ឃឹមថានឹងដឹកនាំកិច្ចប្រឹងប្រែងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល សំរាប់រយៈពេលពី ២០០៦ ទៅ ២០១០ ។ វាត្រូវបានសម្តេចនាយករដ្ឋមន្ត្រីចាត់ទុកថាជា "ផែនការមួយសំរាប់ការរីកចំរើនបន្ថែមទៀត" និងជា "ជាឯកសារគោលតែមួយសំរាប់រយៈពេល៥ឆ្នាំទៀតខាងមុខ" ។ ទោះជាផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិគឺជាការងារមិនទាន់ចប់សព្វគ្រប់ ហើយកំពុងរងចាំផែនការតាមវិស័យជាច្រើនទៀតក៏ដោយ ក៏វាអាចបង្ហាញអោយឃើញនូវការបែងចែកថវិកាតាមវិស័យនៅក្នុងតារាង ៥.២ ដែលផ្តល់នូវការយល់ដឹងស៊ីជំរៅអំពីអត្ថិភាពរបស់វានៅកំរិតជារួមមួយ ។

ការពិតដែលថា នាពេលបច្ចុប្បន្ននេះវាមិនមានគ្នាទំនាក់ទំនងរវាងគំរោងថវិកាឆ្នាំនេះ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ យើងអាចយល់បានដោយងាយព្រោះថា ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិមិនទាន់បានធ្វើចប់ទាន់ពេលដើម្បីអោយផែនការនេះអាចប្រើជាគោលក្នុងការរៀបចំបែងចែកថវិកា ។ សេចក្តី សង្ខេបរបស់ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបានទទួលស្គាល់ករណីនេះ ហើយធ្វើការសំគាល់ថា "ច្បាប់ថវិកាប្រចាំឆ្នាំ និងឆ្លើយតបទៅនឹងគំរោងយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងកម្មវិធីវិនិយោគសាធារណៈចាប់ពីឆ្នាំ ២០០៧ ទៅ" ។ កម្មវិធីវិនិយោគសាធារណៈ ២០០៦-២០០៨ " បានផ្តល់នូវពត៌មានលំអិតអំពីកម្មវិធី និងគំរោងដែលរាជរដ្ឋាភិបាលមានគោលបំណងអនុវត្តដើម្បីសំរេចគោលដៅអត្ថិភាព យុទ្ធសាស្រ្ត និងសកម្មភាពដែលបានកំណត់នៅក្នុងសេចក្តីព្រាងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០០៦-២០១០"[១៩] ក៏មិនមានទំនាក់ទំនងទៅនឹងគំរោងថវិកាជាតិដែរ ។

តារាងទី ៣ គឺជាសេចក្តីសង្ខេបនៃ ឧបសម្ព័ន្ធទី ២ ដែលបានផ្តល់នូវការបូកសរុបយ៉ាងពេញលេញអំពីច្បាប់ថវិកាជាតិឆ្នាំ ២០០៦ និងការផ្គូរផ្គងចំណាយដែលកំណត់នៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងកម្មវិធីវិនិយោគសាធារណៈសំរាប់ឆ្នាំ ២០០៦ ។ ទោះជាការវិភាគនេះជួបការលំបាកដោយសារកង្វះខាតព័ត៌មានលំអិតអំពីចំណាយមូលធននៅក្នុងផ្នែកតូចៗនៃវិស័យនីមួយៗ និងកំហុសដែលអាចកើតឡើងដោយសារការផ្គូរផ្គងមិនត្រូវគ្នារវាងចំណងជើងដែលមាននៅក្នុងកម្មវិធីអភិវឌ្ឍន៍សាធារណៈ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិជាមួយនឹងចំណងជើងនៅក្នុងគំរោងថវិកាជាតិក៏ដោយ ក៏ការវិភាគនេះអាចឆ្លុះបញ្ចាំងយ៉ាងច្បាស់លាស់នូវបញ្ហាពីរដែលចាំបាច់ត្រូវដោះស្រាយនៅឆ្នាំ២០០៧ ។

[១៩] កម្មវិធីវិនិយោគសាធារណៈ ២០០៦-២០០៨ ទំព័រ ii

១. ភាពមិនស្របគ្នារវាងច្បាប់ថវិកាជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ភាពខុសគ្នានៃចំនួនថវិកាដែលបានបែងចែកទៅឱ្យចំណាយចរន្ត ដែលមានក្នុងច្បាប់ថវិកាជាតិធៀបនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺមានប្រមាណ ៥ លានដុល្លារ សំរាប់វិស័យអប់រំ ៥៨ លានដុល្លារ សំរាប់វិស័យសុខាភិបាល និងអវិជ្ជមានសំរាប់វិស័យសង្គមកិច្ច ។

២. មានភាពខុសគ្នាយ៉ាងច្រើនរវាងការបែងចែកចំណាយតាមវិស័យក្នុងកម្មវិធីវិនិយោគសាធារណៈ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ភាពខុសគ្នានេះបង្ហាញអោយឃើញថា មានភាពចាំបាច់ក្នុងការផ្តល់អាទិភាពដល់គំរោងដែលមាននៅក្នុងកម្មវិធីវិនិយោគសាធារណៈដើម្បីអោយវាឆ្លើយតបទៅនឹងអាទិភាពដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

**តារាងទី៣:** ការបែងចែកថវិកាក្នុងផែនការអភិវឌ្ឍន៍ជាតិ និងការផ្គូរផ្គង់ចំណាយចរន្តថវិកាជាតិ ឆ្នាំ២០០៦

| | Budget Law | NSDP | Share | PIP | Share |
|---|---|---|---|---|---|
| *ចំណាយចរន្ត សរុប* | ***៥៧៥*** | | | | |
| I. រដ្ឋបាលទូទៅ | ៨៤ | ៤៤ | ៧% | ៥០ | ៨% |
| II. ការពារ និងសន្តិសុខ | ១១៦ | | | | |
| III. រដ្ឋបាលសាធារណៈ | ២០៨ | | | | |
| ១២. *សុខភាពសាធារណៈ* | *៦២* | *១២០* | *២០%* | *៩០* | *១៥%* |
| ១៦. *អប់រំយុវជន និងកីឡា* | *១០៥* | *១១០* | *១៨%* | *៧២* | *១២%* |
| ១៩. *បរិស្ថាន* | *២* | *២០* | *៣%* | *១៩* | *៣%* |
| ២១. *សង្គមកិច្ច ការងារ និង បណ្តុះបណ្តាលវិជ្ជាជីៈ* | *២៦* | *១៦* | *៣%* | *៧* | *១%* |
| ២៤. *កិច្ចការនារី និងយុវនិតិសម្បទា* | *៣* | *៦* | *១%* | *៥* | *១%* |
| IV. *រដ្ឋបាលសេដ្ឋកិច្ច* | ៩៥ | | | | |
| ១៣. *ឧស្សាហកម្ម រ៉ែ និងថាមពល* | *២* | *៤០* | *៧%* | *៤៥* | *៨%* |
| ១៧. *កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* | *១៤* | *៧០* | *១២%* | *៦២* | *១០%* |
| ២០. *អភិវឌ្ឍន៍ជនបទ* | *៨* | *៧០* | *១២%* | *៨១* | *១៤%* |
| ២៥. *សាធារណការ និងដឹកជញ្ជូន* | *៤* | *១១០* | *១៨%* | *១២២* | *២០%* |
| V. *ផ្សេងៗ* | ១១១ | | | | |
| *ចំណាយមូលធនសរុប* | *៣៣៣* | | | | |
| ***សរុប*** | ៩០៨ | ៦០៦ | *១០០%* | ៥៩៩ | *១០០%* |

*ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០០៦ ក្រសួងផែនការ (NSDP ២០០៦-២០១០, PIP ២០០៦-២០០៨)*

## ឧបសម្ព័ន្ធទី ១

**តារាងទី ១:** អតិផរណា និងកត្តាបរិត្តផរណាដែលបានគណនា

| | ២០០៤ | ២០០៥ | ២០០៦ |
|---|---|---|---|
| អតិផរណា ជារៀល * | ៣.៩ | ៥.៨ | ... |
| កត្តាបរិត្តផរណា | ០.៩១ | ០.៩៤ | ១ |

** អ្នកឃ្លាំមើលសេដ្ឋកិច្ចកម្ពុជា វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា មេសា ២០០៦*

## តារាងទី២: ចំណាយចរន្តរបស់រាជរដ្ឋាភិបាល នៅក្នុងច្បាប់ថវិកាជាតិ និងការអនុវត្តន៍

| លានរៀល | ច្បាប់ថវិការ ២០០៤ | % | ការអនុវត្តន៍ ២០០៤ | % | ច្បាប់ថវិការ ២០០៥ | % | ការអនុវត្តន៍ ២០០៥ | % | ច្បាប់ថវិការ ២០០៦ | % |
|---|---|---|---|---|---|---|---|---|---|---|
| ចំណាយចរន្តសរុប | ២.០៨៨.៨៥៨ | ១០០% | ១.៩២៧.៨១៥ | ១០០% | ២.១០៥.៧៣២ | ១០០% | ២.០៨៨.៩៥៣ | ១០០% | ២.៤១៤.២៥៥ | ១០០% |
| I. រដ្ឋបាលទូទៅ | ៣០២.០០១ | ១៤.៥% | ៣៣៣.៣១៧ | ១៧.៣% | ៣០៨.២៣២ | ១៤.៦% | ៣៧៧.៩៧៤ | ១៨.១% | ៣៩៣.៤៥៤ | ១៤.៦% |
| ០១. ព្រះបរមរាជវាំង | ២៤.៥២៣ | ១.២% | ២៤.៧១៧ | ១.៣% | ២៣.៣២៣ | ១.១% | ៣៨.៤១៦ | ១.៨% | ៣៧.០៣៣ | ១.៥% |
| ០២. រដ្ឋសភា | ៣៩.២១៥ | ១.៩% | ៤៦.៥២៨ | ២.៤% | ៤២.៤៦៣ | ២.០% | ៤២.៤៦៣ | ២.០% | ៤៧.៦០៤ | ២.០% |
| ០៣. ព្រឹទ្ធសភា | ២០.៦៥៧ | ១.០% | ១៩.៧៩២ | ១.០% | ១៩.៣៧៤ | ០.៩% | ១៩.៧៩៣ | ០.៩% | ២០.២៦០ | ០.៨% |
| ០៤. ក្រុមប្រឹក្សាធម្មនុញ្ញ | ៣.៧៥៦ | ០.២% | ៣.៧១៣ | ០.២% | ៣.៥១៤ | ០.២% | ៣.៤៨៨ | ០.២% | ៣.៤៧០ | ០.១% |
| ០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី | ៦៣.២៩៧ | ៣.០% | ៩០.៥២៤ | ៤.៧% | ៦២.៦៦៥ | ៣.០% | ៩៩.៧៥៧ | ៤.៨% | ៦៣.៥១៧ | ២.៦% |
| ០៥.២. លេខាធិការសេវាសាធារណៈ | ១.៤៣៦ | ០.១% | ១.៣៥១ | ០.១% | ១.៣៦៤ | ០.១% | ២.២០៧ | ០.១% | ១.៥១៧ | ០.១% |
| ០៥.៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ៤.៣០៨ | ០.២% | ៣.៤៩៣ | ០.២% | ៣.៩៩៩ | ០.២% | ៣.៩៧៣ | ០.២% | ៣.៩៣៧ | ០.២% |
| ០៧.២. រដ្ឋបាល មហាផ្ទៃ | ១៩.៤៤២ | ០.៩% | ១៨.៥៥០ | ១.០% | ១៨.១១០ | ០.៩% | ២១.៦៥៧ | ១.០% | ១៩.៨៧០ | ០.៨% |
| ០៨. ទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច | ៣.១៧០ | ០.២% | ២.៤១៨ | ០.១% | ៤.២២២ | ០.២% | ៣.៨៧៥ | ០.២% | ៥.៣៦៤ | ០.២% |
| ០៩. ការបរទេស និងទំនាក់ទំនងអន្តរជាតិ | ៥៧.៤៤២ | ២.៧% | ៥៤.៧៦៥ | ២.៨% | ៥៣.៩៧៦ | ២.៦% | ៦០.៥៨៣ | ២.៩% | ៥៨.៤០០ | ២.៤% |
| ១០. សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៣៥.៥១៨ | ១.៧% | ៣៩.៣៥៦ | ២.០% | ៣៤.៦១៨ | ១.៦% | ៤២.៨៧៧ | ២.១% | ៣៨.៨៣៨ | ១.៦% |
| ១៤. ផែនការ | ៦.១២៥ | ០.៣% | ៥.៦០៣ | ០.៣% | ៦.២២១ | ០.៣% | ៦.៧៣១ | ០.៣% | ៧.៣៣៧ | ០.៣% |
| ២៦. យុត្តិធម៌ | ១៤.២១៧ | ០.៧% | ១១.៩៧៥ | ០.៦% | ១៣.៩៤២ | ០.៧% | ១២.៤៥៥ | ០.៦% | ១៤.៤៤៥ | ០.៦% |
| ៣០.គណៈកម្មាការជាតិបោះឆ្នោត | ៣.៤៨០ | ០.២% | ៦.៨៤៨ | ០.៤% | ២.៧៧៦ | ០.១% | ៦.៣៨៥ | ០.៣% | ៥.៤៤៥ | ០.២% |
| ៣១.អាជ្ញាធរសវនកម្មជាតិ | ៥.១១៥ | ០.២% | ៣.៦៣២ | ០.២% | ៤.៨៥៤ | ០.២% | ៣.៩៦១ | ០.២% | ៥.៣៨១ | ០.២% |
| ៣២. កិច្ចការ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ០.០% | | ០.០% | ១២.៨២៤ | ០.៦% | ៩.៤៤៥ | ០.៥% | ២០.៩៨២ | ០.៩% |
| ការពារ និងសន្តិសុខ | ៤៧៨.៤២៥ | ២២.៩% | ៤៦៧.០៦៩ | ២៤.២% | ៤៨០.០៤២ | ២២.៨% | ៤៧៨.៩៦៣ | ២២.៩% | ៤៨៧.៨៦០ | ២០.២% |
| ០៦. ការពារជាតិ | ៣០៧.០៨៣ | ១៤.៧% | ៣០០.១៧៧ | ១៥.៦% | ៣០៨.២៨០ | ១៤.៦% | ៣០៧.១៩០ | ១៤.៧% | ៣១១.៣៦០ | ១២.៩% |
| ០៧. សន្តិសុខ | ១៧១.៣៣២ | ៨.២% | ១៦៦.៨៩២ | ៨.៧% | ១៧១.៧៦២ | ៨.២% | ១៧១.៧៧៣ | ៨.២% | ១៧៦.៥០០ | ៧.៣% |
| រដ្ឋបាលសង្គម | ៨០៧.០៧០ | ៣៨.៦% | ៧៩២.៦៤៤ | ៣៨.៥% | ៧៩៦.៤៧០ | ៣៧.៨% | ៧៦៥.២៥៧ | ៣៦.៦% | ៨៧៤.៦៨៦ | ៣៦.២% |
| ១១. ពត៌មាន | ១៤.៥០២ | ០.៧% | ១៤.១១៧ | ០.៧% | ១៤.០៣៩ | ០.៧% | ១៣.៥៨១ | ០.៧% | ១៦.៦០៦ | ០.៧% |
| ១២. សុខាភិបាលសាធារណៈ | ២៥១.៤១៩ | ១២.០% | ២១២.១៦២ | ១១.០% | ២៥៣.៥១៤ | ១២.០% | ២៣៨.៣៧៦ | ១១.៤% | ២៦០.៩៧៣ | ១០.៨% |
| ១៦. អប់រំ យុវជន និងកីឡា | ៣៩២.២៦២ | ១៨.៨% | ៣៦០.០១៥ | ១៨.៧% | ៣៨៩.៣៣៧ | ១៨.៥% | ៣៧២.៣៦៥ | ១៧.៨% | ៤៤២.០០០ | ១៨.៣% |
| ១៨.វប្បធម៌ និងវិចិត្រសិល្បៈ | ១៦.១២៨ | ០.៨% | ១៣.៧៥៦ | ០.៧% | ១៥.២៥៧ | ០.៧% | ១៩.១៤០ | ០.៧% | ១៥.៦៦៥ | ០.៦% |
| ១៩.បរិស្ថាន | ៩.៧១៥ | ០.៥% | ៨.១៤៨ | ០.៤% | ៩.២៦៨ | ០.៤% | ៨.៧៣៨ | ០.៤% | ៩.៣៩៣ | ០.៤% |
| ២១. សង្គមកិច្ច ការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ | ៣៧.៩០១ | ១.៨% | ៣៦.០០៣ | ១.៩% | ៩៨.៧៩៧ | ៤.៧% | ១០១.២៤៤ | ៤.៨% | ១១០.៨៤៥ | ៤.៦% |
| ២៣.ធម្មការ និងកិច្ចការសាសនា | ៤.៦១៧ | ០.២% | ៣.៨៦៣ | ០.២% | ៤.៤៣៧ | ០.២% | ៤.៣៧៧ | ០.២% | ៥.៧៥៤ | ០.២% |
| ២៤. កិច្ចការនារី និងយុវតិតិសម្បទា | ៨០.១២៦ | ៣.៨% | ៩៤.៥៣៩ | ៤.៩% | ១១.៨៣១ | ០.៦% | ១០.៩៧៧ | ០.៥% | ១៣.៤៤២ | ០.៦% |
| រដ្ឋបាលសេដ្ឋកិច្ច | ២២០.៨២០ | ១០.៦% | ១៦៧.០៩៧ | ៨.៧% | ២១២.២៧៧ | ១០.១% | ១៨៩.០៧៧ | ៩.១% | ២៣២.១០១ | ៩.៦% |
| ០៥.៣. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ៩.៥០០ | ០.៥% | ៦.៦៥៦ | ០.៣% | ៨.៤៤៤ | ០.៤% | ៧.៦៥៣ | ០.៤% | ៨.៩៦០ | ០.៤% |
| ១៣. ឧស្សាហកម្ម រ៉ែ និងថាមពល | ៨.៧៨២ | ០.៤% | ៦.៨៣២ | ០.៤% | ៨.៤៩៣ | ០.៤% | ៧.៨០៥ | ០.៤% | ៩.១២៤ | ០.៤% |
| ១៥. ពាណិជ្ជកម្ម | ២០.១០៥ | ១.០% | ១៣.៤៤៥ | ០.៧% | ១៥.០៥៥ | ០.៧% | ១៥.៤៨៨ | ០.៧% | ២១.៤៨៨ | ០.៩% |
| ១៧. កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៥២.៦៥២ | ២.៥% | ៤២.៥៨៧ | ២.២% | ៥៣.២២២ | ២.៥% | ៥០.០១០ | ២.៤% | ៥៦.៨១៥ | ២.៤% |
| ២០. អភិវឌ្ឍន៍ជនបទ | ២៦.០៧០ | ១.២% | ១៨.៣៦៧ | ១.០% | ២៦.១៩២ | ១.២% | ២៣.៥០៧ | ១.១% | ៣៣.២០៦ | ១.៤% |
| ២២. ប្រៃសណីយ៍ និងទូរគមនាគមន៍ | ៤៣.៣៥២ | ២.១% | ២៧.៥១៥ | ១.៤% | ៣៥.៨២០ | ១.៩% | ៣២.៧៥៧ | ១.៦% | ៣៣.៩៣៨ | ១.៤% |
| ២២. សាធារណការ និងដឹកជញ្ជូន | ១៦.៨៥០ | ០.៨% | ១៣.៨៣១ | ០.៧% | ១៦.៤១២ | ០.៨% | ១៣.៧៧១ | ០.៧% | ១៨.៤៧៨ | ០.៨% |
| ២៧. ទេសចរណ៍ | ១៦.៤៨១ | ០.៨% | ១៤.២៣៥ | ០.៧% | ១៥.១៤៥ | ០.៧% | ១៥.១៤៥ | ០.៧% | ១៧.៣៩០ | ០.៧% |
| ២៨. រៀបចំដែនដី នគររូបនីយកម្ម និងសំណង់ | ៩.២១៨ | ០.៤% | ៧.៧៨៣ | ០.៤% | ៨.៧២៦ | ០.៤% | ៨.៣៥០ | ០.៤% | ១២.៩៩៩ | ០.៥% |
| ២៥. ធនធានទឹក និងឧតុនិយម | ១៧.៧៣០ | ០.៨% | ១៥.៨០២ | ០.៨% | ១៦.៣០៦ | ០.៨% | ១៤.៥៥១ | ០.៧% | ២០.២០៧ | ០.៨% |
| ផ្សេងៗ | ២៨០.៥៨២ | ១៣.៤% | ២១៧.៧៣៣ | ១១.៣% | ៣០៨.៧១០ | ១៤.៧% | ២៧៧.៧៣១ | ១៣.៣% | ៤៦៦.១៥៥ | ១៩.៣% |
| ជំពូក ១២. ប្រាក់ឧបត្ថម្ភជូនរដ្ឋបាលខេត្ត ក្រុង | ៩៩.៤១៥ | ៤.៨% | ៩៦.១០៥ | ៥.០% | ១០០.៨៤៥ | ៤.៨% | ១០០.៨៤៥ | ៤.៨% | ១១៦.៦១៤ | ៤.៨% |
| ជំពូក ២០. ការប្រាក់ | ៤៩.៧០៥ | ២.៤% | ៥៣.៦៨៩ | ២.៨% | ៥៣.០៧៩ | ២.៥% | ៥៨.៤៤១ | ២.៨% | ៥០.០០០ | ២.១% |
| ជំពូក ៣០. គន្លាកមូលនិធិសេដ្ឋកិច្ច | | ០.០% | | ០.០% | | ០.០% | ៧៤.៣១២ | ៣.៦% | | ០.០% |
| ជំពូក ៤០. ផ្សេងៗ | ១០៩.៣៦១ | ៥.២% | ១២.១៤៣ | ០.៦% | ១៣៣.៥៥១ | ៦.៣% | ៤៤.១២៨ | ២.១% | ២៦៧.៥៤០ | ១១.១% |
| ជំពូក ៤១. ចំណាយមិនបានគ្រោងទុក | | ០.០% | | ០.០% | ២១.២៣១ | ១.០% | | ០.០% | ៣២.០០០ | ១.៣% |

*ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០០៤ ២០០៥ និង ២០០៦*

*(ទិន្ន័យសំរាប់ឆ្នាំ២០០៤ និង ២០០៥ ត្រូវបានកែសំរួលទៅតាមអត្រាបរិត្តផរណា ដែលមាននៅក្នុង តារាងទី១)*

**ឧបសម្ព័ន្ធទី២:** ការបែងចែកថវិកានៅក្នុងច្បាប់ថវិកា កម្មវិធីវិនិយោគសាធារណៈ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០០៦

| ច្បាប់ថវិកាជាតិ | | កម្មវិធីវិនិយោគសាធារណៈ | កំពុងដំណើរការ | ចុះកិច្ចព្រមព្រៀងហើយ | កំពុងចរចារ អង្គភាពខ្ចី | សរុប | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
|---|---|---|---|---|---|---|---|
| ចំណាយចរន្តសរុប | ៥៧៥ | | | | | | |
| **I.** រដ្ឋបាលទូទៅ | ៨៤ | *"ការអភិវឌ្ឍន៍ និងអភិបាលកិច្ច"* | ៣៦ | ៨ | ៥ | ៥០ | ៤៤ |
| **II.** ការពារ និងសន្តិសុខ | ១១៦ | | | | | | |
| **III.** រដ្ឋបាលសង្គម | ២០៨ | | | | | | |
| ១១. ពត៌មាន | *៤* | *"ពត៌មាន"* | ១ | ០ | ២ | ៣ | |
| ១២. សុខភាពសាធារណៈ | *៦២* | *"សុខភាព"* | ៨៥ | ០ | ១ | ៩០ | ១២០ |
| ១៦. អប់រំ យុវជន និងកីឡា | *១០៥* | *"អប់រំ"* | ៦៦ | ២ | ៤ | ៧២ | ១១០ |
| ១៨. វប្បធម៌ និងវិចិត្រសិល្បៈ | *៤* | *"វប្បធម៌ និងវិចិត្រសិល្បៈ"* | ០ | ០ | ៣ | ៣ | ៦ |
| ១៩. បរិស្ថាន | *២* | *"បរិស្ថាន និងការការពារ"* | ១៥ | ១ | ២ | ១៩ | ២០ |
| ២១. សង្គមកិច្ច ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | *២៦* | *"សង្គមកិច្ច និងសេវាកម្មសហគមន៍"* | ៤ | ០ | ៣ | ៧ | ១៦ |
| ២៣. ធម្មការ និងកិច្ចការសាសនា | *១* | *"កិច្ចការសាសនា"* | ០ | ០ | ១ | ១ | |
| ២៤. កិច្ចការនារី និងយុវនិតិសម្បទា | *៣* | *"តំរោងពិសេស"* | ២ | ២ | ០ | ៥ | ៦ |
| **IV.** រដ្ឋបាលសេដ្ឋកិច្ច | ៥៥ | | | | | | |
| *០៥.៣. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល* | ២ | | | | | | |
| *១៣. ឧស្សាហកម្ម រ៉ែ និងថាមពល* | ២ | *"ថាមពល" + "ពាណិជ្ជកម្ម និងឧស្សាហកម្ម"* | ១៨ | ១៥ | ៨ | ៤៥ | ៤០ |
| *១៥. ពាណិជ្ជកម្ម* | ៥ | | | | | | |
| *១៧. កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* | ១៤ | *"កសិកម្ម"* | ៤៥ | ៣ | ១៥ | ៦២ | ៧០ |
| *២០. អភិវឌ្ឍន៍ជនបទ* | *៨* | *"អភិវឌ្ឍន៍ជនបទ"* | ៦៥ | ៣ | ១៣ | ៨១ | ៧០ |
| *២២ ប្រៃសណីយ៍ និងទូរគមនាគមន៍* | *៨* | *"ទូរគមនាគមន៍"* | ៣ | ១ | ២ | ៦ | ១២ |
| *២២. សាធារណការ និងដឹកជញ្ជូន* | *៤* | *"ដឹកជញ្ជូន (ផ្លូវគោក កំពង់ផែ ផ្លូវដែក និងផ្លូវអាកាស)"* | ៩៨ | ១១ | ១៣ | ១២២ | ១១០ |
| *២៧. ទេសចរណ៍* | *៤* | *"ទេសចរណ៍"* | ៦ | ០ | ៤ | ១០ | ៦ |
| *២៨. រៀបចំដែនដី នគរូបនីយកម្ម និងសំណង់* | *៣* | | | | | | |
| *២៩. ធនធានទឹក និងឧតុនិយម* | *៥* | *"ផ្គត់ផ្គង់ទឹក និងអនាម័យ"* | ៩ | ១២ | ៣ | ២៤ | ៣០ |
| **V.** *ផ្សេងៗ* | ១១១ | | | | | | |
| | | - សរុប កំពុងដំណើរការ | | | | ៤៥៧ | |
| ចំណាយមូលធនសរុប | ៣៣៣ | - សរុប ចុះកិច្ចព្រមព្រៀងហើយ | | | | ៦៣ | |
| - មូលធនក្នុងស្រុក (ជំពូក ៥០) | ១០៦ | - សរុប កំពុងចរចាអង្គភាព | | | | ៧៩ | |
| -មូលធនពីក្រៅប្រទេស | ២០៤ | | | | | | |
| - ការសងបំណុលបរទេស | ២៣ | | | | | | |
| សរុប | *៩០៨* | | | | | *៥៩៩* | *៦៦០* |

*ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ (NSDP ២០០៦-២០១០, PIP ២០០៦-២០០៨)*

**អត្រាប្តូរប្រាក់ ១ដុល្លារ = ៤២០០រៀល*

*រៀបរៀងដោយបណ្តាញការងារអភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្ម*
*ទំនាក់ទំនង: លោក រស់ ខេមរា*
*ទូរស័ព្ទលេខ: 855-12 692 928*
*Email: khemara@ngoforum.org.kh*